ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

# ផែនការយុទ្ធសាស្ត្រថវិកា
# ០៣ឆ្នាំរំកិល ២០២៦-២០២៨
# និងផែនការថវិកាប្រចាំ
# ឆ្នាំ២០២៦

ខែមករា ឆ្នាំ២០២៦

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ :............✓...............

# ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦ - ២០២៨
# អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

## I. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភាបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ក្នុងគោលបំណងសម្រេចឱ្យបាននូវកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាពកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ដើម្បីចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យ ដែលបានកំណត់ ក្រសួងមហាផ្ទៃមានសមត្ថកិច្ច ដឹកនាំគ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់ លើវិស័យរដ្ឋបាល ដឹកនាំគ្រប់គ្រងនគរបាលជាតិ ការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការពារសុវត្ថិភាពជូនប្រជាពលរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះ អគ្គនាយកដ្ឋានរដ្ឋបាល គឺជាអង្គភាពមួយក្នុងចំណោម អង្គភាពចំណុះទាំង១៥ នៃក្រសួងមហាផ្ទៃ មានតួនាទីធ្វើជាសេនាធិការ ក្នុងការគ្រប់គ្រងរដ្ឋបាលដែនដី ដោយផ្អែកលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងសម្របសម្រួលក្នុងការបង្កើត ការចុះបញ្ជី និងគ្រប់គ្រងសកម្មភាពសមាគម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជនជាតិដើមភាគតិច និងគណបក្សនយោបាយ។ ផ្អែកលើក្របខណ្ឌច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ បានប្រព្រឹត្តទៅប្រកបដោយជោគជ័យ។ ទន្ទឹមនោះ ច្បាប់រៀបចំអង្គការដែលបានបង្កើតឡើងមានគោលដៅគាំទ្រដល់ការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយរៀបចំបង្កើត និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅជំរុញ កែលម្អការគ្រប់គ្រងរដ្ឋបាល និងបង្កើនការអភិវឌ្ឍនៅមូលដ្ឋានលើគ្រប់វិស័យឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងលើកកម្ពស់ការផ្តល់សេវាសាធារណៈ ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ជាទឡ្ហីករណ៍ក្នុងការអនុវត្តនូវកិច្ចការខាងលើ ក្នុងឆ្នាំ២០២៤កន្លងមក អគ្គនាយកដ្ឋានរដ្ឋបាល បានយកចិត្តទុកដាក់យ៉ាងម៉ឺងម៉ាត់ក្នុងការអនុវត្តតួនាទីភារកិច្ច និងសម្រេចបានលទ្ធផលការងារជាច្រើន រួមមានដូចខាងក្រោម៖

### ១. តួនាទី និងបេសកកម្មចម្បងៗ

-សិក្សា និងលើកយោបល់ក្នុងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានជាធរមាន

-រៀបចំប្រព័ន្ធគាំទ្រ និងសម្របសម្រួលទៅលើការបំពេញតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍អំពីការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

-រៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើការបំពេញតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកិច្ចដំណើរការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សហការសម្របសម្រួលក្នុងការលើកកម្ពស់ប្រសិទ្ធភាព នៃការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ

-រៀបចំប្រព័ន្ធ និងនីតិវិធីសម្រាប់គាំទ្រដល់ការសម្របសម្រួល និងដោះស្រាយវិវាទនៅមូលដ្ឋាន

-គ្រប់គ្រងសកម្មភាពរបស់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនគោក ច្រកទ្វារព្រំដែនសមុទ្រ និងសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សហការសម្របសម្រួល និងគាំទ្រនៅក្នុងការរៀបចំ ការគ្រប់គ្រង និងការអនុវត្តគម្រោងកម្មវិធីនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅមូលដ្ឋាន

-សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំគោលនយោបាយអភិវឌ្ឍន៍ទីក្រុង និងទីប្រជុំជននានា

-សហការគាំទ្រ និងតាមដានដំណើរការ នៃការផ្ទេរធនធានថវិកាឱ្យទៅថ្នាក់ក្រោមជាតិ

-ត្រួតពិនិត្យនីត្យានុកូលភាពដីកា និងសេចក្តីសម្រេចនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-លើកសំណើរកែសម្រួលច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានា ដែលផ្ទុយនឹងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ

-សិក្សា ពិនិត្យ និងលើកយោបល់ពាក់ព័ន្ធនឹងការបង្កើត ឬការលុបចោលភូមិ

-ណែនាំលើការងារគ្រប់គ្រង និងការប្រើប្រាស់ត្រានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សម្របសម្រួលលើសំណើសុំបង្កើត និងចុះបញ្ជីគណបក្សនយោបាយ ព្រមទាំងការបំពេញមុខងារពាក់ព័ន្ធគណបក្សនយោបាយស្របតាមការកំណត់របស់ច្បាប់

-សម្របសម្រួលលើសំណើសុំចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងតាមដានត្រួតពិនិត្យការអនុវត្តសកម្មភាពស្របតាមលក្ខន្តិកៈនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់និងលិខិតបទដ្ឋាននានាជាធរមាន

-បំពេញការងារពាក់ព័ន្ធនឹងមន្ត្រីរាជការដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃស្របតាមច្បាប់និងលិខិតបទដ្ឋានជាធរមាន

-សហការរៀបចំ និងដាក់ឱ្យអនុវត្ត ព្រមទាំងតាមដាន និងត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍស្ថាប័នការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៅថ្នាក់ក្រោមជាតិ

-សហការរៀបចំប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្ស និងផែនការបណ្តុះបណ្តាល អប់រំ កសាងសមត្ថភាពដល់មន្ត្រីរាជការស៊ីវិលនៅអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-រៀបចំបែបបទផ្លាស់ប្តូរ និងទទួលស្គាល់សមាជិកក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមច្បាប់កំណត់

-រៀបចំសំណុំឯកសារ និងទិន្នន័យមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ សមាជិកក្រុមប្រឹក្សា និងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ កៀរគរប្រភពធនធាន និងមូលនិធិដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រ និងអនុវត្តនូវកម្មវិធី និងគម្រោងនានាសម្រាប់គាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

-រៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិការបស់អគ្គនាយកដ្ឋានរដ្ឋបាល

-រៀបចំ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយកដ្ឋានរដ្ឋបាល

-ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលការងាររបស់អគ្គនាយកដ្ឋានរដ្ឋបាលតាមការកំណត់

-បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ២. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤ (ធៀបសូចនាករដែលបានកំណត់)

### ២.១-ការងារលិខិតស្នាម និងឯកសារផ្សេងៗ

ដើម្បីធានាឱ្យកិច្ចប្រតិបត្តិការការងាររបស់អង្គភាពនានាចំណុះក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសធានាការអនុវត្តកម្មវិធីកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ២០២៤ កន្លងមកនេះ អគ្គនាយកដ្ឋានរដ្ឋបាលបានទទួលលិខិត និងឯកសារដែលបញ្ជូនមកពីអគ្គលេខាធិការដ្ឋាន និងអង្គភាពនានាចំណុះក្រសួងមហាផ្ទៃសរុបចំនួន **១០.១០២ច្បាប់** ក្នុងនោះបានចាត់ចែងបញ្ជូនលិខិតជូនថ្នាក់ដឹកនាំដើម្បីពិនិត្យសម្រេចចំនួន **៦.៥១៧ច្បាប់** (ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃពិនិត្យសម្រេចចំនួន **៣.៦៤៥ច្បាប់** និងជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានរដ្ឋបាលចំនួន **២.៨៧២ច្បាប់**) និងតម្កល់ទុកជាឯកសារចំនួន **៣.៥៨៥ច្បាប់**។ ទន្ទឹមនេះ អគ្គនាយកដ្ឋានបានទទួលលិខិត និងឯកសារ ដែលថ្នាក់ដឹកនាំក្រសួងមហាផ្ទៃពិនិត្យ សម្រេចរួចចំនួន **៣.៧១៤ច្បាប់**។

ចំពោះការងារចេញលិខិត អគ្គនាយកដ្ឋានរដ្ឋបាលបានចេញលិខិតបង្គាប់ការ និងលិខិតបញ្ជាបេសកកម្មសរុបចំនួន **១.២១៤ច្បាប់** (ក្នុងនោះលិខិតបង្គាប់ការចំនួន **៥៩០ច្បាប់** និងលិខិតបញ្ជាបេសកកម្មចំនួន **៦២៤ច្បាប់**) ជូនថ្នាក់ដឹកនាំ និងមន្ត្រីចំណុះអគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីចុះទៅបំពេញបេសកកម្មនៅតាមបណ្ដាខេត្តនានា។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានចុះទិដ្ឋាការជូនមន្ត្រីរាជការមកពីបណ្ដាខេត្តដែលមកបំពេញ បេសកកម្មនៅក្រសួងមហាផ្ទៃផងដែរ។

ក្នុងឆ្នាំ២០២៤នេះដែរ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានបានរៀបចំ និងកិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ដូចខាងក្រោម៖

- បានចូលរួមកម្មវិធី កិច្ចប្រជុំ និងសិក្ខាសាលានានាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នាឱកាសទទួលជួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ និងអន្តរជាតិចំនួន **៦៧លើក**
- បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សា សន្និបាត សិក្ខាសាលា សន្និសីទ វគ្គបណ្ដុះបណ្ដាល ជាវាគ្មិនដឹកនាំការប្រជុំ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាចំនួន **៥៨៨លើក**
- បានរៀបចំកិច្ចប្រជុំ សិក្ខាសាលាផ្ទៃក្នុង និងសហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាចំនួន **១០៥លើក**។

### ២.២-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្អែកតាមច្បាប់ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ មានអាណត្តិការងាររយៈពេល០៥ឆ្នាំ និងត្រូវបានផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ និងសេចក្ដីសម្រេចខាងប្រតិបត្តិ។ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចខាងបញ្ញត្តិតាមរយៈការចេញដីកា និងមានសិទ្ធិអំណាចខាងប្រតិបត្តិតាមរយៈការធ្វើសេចក្ដីសម្រេចចិត្តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា។ ផ្អែកតាមគោលការណ៍បានកំណត់ខាងលើ អគ្គនាយកដ្ឋានរដ្ឋបាលបានសហការសម្របសម្រួល និងគាំទ្រដល់ដំណើរការការងារសំខាន់ៗពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសម្រាប់អាណត្តិទី៤ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៤ ដើម្បីធានាឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះប្រព្រឹត្តទៅតាមរបបដែលបានកំណត់ និងស្របតាមច្បាប់ បទបញ្ញានិងនីតិវិធីនៃការបោះឆ្នោត ដែលធានាបាននូវស្ថិរភាពនយោបាយ ប្រក្រតីភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

វឌ្ឍនភាពការងារសំខាន់ៗដែលអគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តសម្រេចបានរួមមាន៖

- ការកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៤

- ការកំណត់អាសនៈក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៤

- ការពិនិត្យ និងផ្តល់យោបល់លើបទបញ្ញា និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៤

- ការរៀបចំព្រះរាជក្រឹត្យ និងអនុក្រឹត្យទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៤

- ការពិនិត្យ និងកែសម្រួលនូវគំរូបទបញ្ញាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ការរៀបចំសេចក្តីណែនាំស្តីពីកិច្ចប្រជុំចូលកាន់តំណែង កិច្ចប្រជុំសាមញ្ញលើកទី១ និងកិច្ចប្រជុំសាមញ្ញលើកទី២ របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ការរៀបចំសេចក្តីណែនាំស្តីពីការរៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារបញ្ចប់អាណត្តិរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៣(២០១៩-២០២៤)។

បច្ចុប្បន្ន សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់មានចំនួនសរុប១៥.៨១៧នាក់ ស្រីមានចំនួន ៣.២៩៤នាក់ ក្នុងនោះរាជធានី ខេត្តមានចំនួន ៥៥៩នាក់ ក្រុង ស្រុក ខណ្ឌមានចំនួន ៣.៦៤១នាក់ និងឃុំ សង្កាត់មានចំនួន ១១.៦២២នាក់។

ទន្ទឹមនេះ អគ្គនាយកដ្ឋានបានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ដើម្បីធ្វើការផ្លាស់ប្តូរ និងទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងនោះរួមមាន៖ សមាសភាពក្រុមប្រឹក្សារាជធានី ខេត្តចំនួន ៨នាក់ សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ២៤នាក់ (ស្រីមានចំនួន១២នាក់) និងសមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ៩៥នាក់ (ស្រីមានចំនួន១៣នាក់)។ អគ្គនាយកដ្ឋានក៏បានរៀបចំចេញប័ណ្ណសម្គាល់ខ្លួនជូនប្រធាន និងសមាជិកក្រុមប្រឹក្សាខេត្តចំនួន ៥ខេត្ត សរុបចំនួន ១០៩ប័ណ្ណ រួមមានខេត្តព្រៃវែងចំនួន ២៧ប័ណ្ណ ខេត្តក្រចេះចំនួន ២១ប័ណ្ណ ខេត្តប៉ៃលិនចំនួន ១៥ប័ណ្ណ ខេត្តព្រះសីហនុចំនួន ១៩ប័ណ្ណ និងខេត្តបាត់ដំបងចំនួន ២៧ប័ណ្ណ។

## ២.៣-ការពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ

### ២.៣.១. រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

#### ២.៣.១.១. ការងារគ្រប់គ្រងដែនដី

ក្នុងឆ្នាំ២០២៤នេះ ដោយផ្អែកលើស្ថានភាពភូមិសាស្ត្រនិងប្រជាសាស្ត្រ ក៏ដូចជាដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការផ្តល់សេវារដ្ឋបាល សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលបានធ្វើការចុះពិនិត្យសិក្សាស្រាវជ្រាវ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ដោយក្នុងនោះបានសម្រេចលើការកែសម្រួលព្រំប្រទល់រវាងរដ្ឋបាលសង្កាត់ចំនួន ១ បង្កើតក្រុងចំនួន ២ ភូមិចំនួន ៤ រួមមានដូចខាងក្រោម៖

- កែសម្រួលព្រំប្រទល់រដ្ឋបាលរវាងសង្កាត់ព្រែកអំពិលជាមួយសង្កាត់កោះឧកញ៉ាតីនៃក្រុងអរិយក្សត្រ ខេត្តកណ្តាល

- បង្កើតក្រុងចំនួន ២ គឺក្រុងរុនតាឯកតេជោសែន ដោយបំបែកចេញពីស្រុកបន្ទាយស្រី និងស្រុកប្រាសាទបាគង នៃខេត្តសៀមរាប និងក្រុងកំពង់សោម ដោយបំបែកចេញពីស្រុកព្រៃនប់ ខេត្តព្រះសីហនុ

- បង្កើតភូមិថ្មីចំនួន ៤ ក្នុងនោះភូមិថ្មីចំនួន ៣ ចំណុះរដ្ឋបាលខេត្តបន្ទាយមានជ័យ និងភូមិថ្មីចំនួន ១ (ភូមិប៊ុនរ៉ានីសែនជ័យដំណាក់ទ្រយឹង) ចំណុះរដ្ឋបាលខេត្តពោធិ៍សាត់។

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានៈ រាជធានីចំនួន ១, ខេត្តចំនួន ២៤, ខណ្ឌចំនួន ១៤, ក្រុងចំនួន ៣៣, ស្រុកចំនួន ១៦៣, សង្កាត់ចំនួន ២៧៤, ឃុំចំនួន ១.៣៧៨ និងភូមិចំនួន ១៤.៥៨១។

ដើម្បីគាំទ្រដល់ដំណើរការយុទ្ធនាការចុះបញ្ជីដីធ្លីទាំងដីរបស់រដ្ឋ និងដីរបស់ប្រជាពលរដ្ឋ ដែលបាននិងកំពុងអនុវត្តយ៉ាងសកម្មស្របតាមទិសដៅដែលបានកំណត់ដោយរាជរដ្ឋាភិបាល និងដើម្បីដោះស្រាយបញ្ចប់នូវភាពមិនច្បាស់លាស់នៃព្រំប្រទល់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានណែនាំដល់រដ្ឋបាលរាជធានីខេត្ត ឱ្យពិនិត្យ និងដោះស្រាយបញ្ហាព្រំប្រទល់រដ្ឋបាលដែលពុំទាន់បានកំណត់ច្បាស់លាស់ ក្នុងករណីដោះស្រាយពុំបាន រដ្ឋបាលរាជធានីខេត្តត្រូវរាយការណ៍ជូនមកក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងដោះស្រាយតាមសមត្ថកិច្ច។

### ២.៣.១.១.២. ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងការរៀបចំ និងពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាល បាននិងកំពុងអនុវត្តកិច្ចការដូចខាងក្រោមៈ

- បានសម្របសម្រួល និងគាំទ្រដល់ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង ការរៀបចំមន្ត្រី និងការរៀបចំដាក់ឱ្យដំណើរការក្រុងរុនតាឯកតេជោសែន នៃខេត្តសៀមរាប និងក្រុងកំពង់សោម នៃខេត្តព្រះសីហនុ ដែលជាក្រុងទើបបង្កើតថ្មី
- បានសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងការរៀបចំវេទិកាសាធារណៈរវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បាននិងកំពុងរៀបចំកែលម្អឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃ លើការបំពេញមុខងាររបស់រដ្ឋបាល
- ថ្នាក់ក្រោមជាតិទាំងបីថ្នាក់ ដើម្បីពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានប្រសិទ្ធភាព និងស្របតាមការវិវត្តនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ចាប់ផ្តើមធ្វើការសិក្សាវាយតម្លៃទៅលើប្រព័ន្ធផែនការនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមានផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល។ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគឺជាផែនទីបង្ហាញផ្លូវ ជារបៀបវារៈនយោបាយរបស់ក្រុមប្រឹក្សា និងជាផែនការយុទ្ធសាស្ត្រនៅក្នុងការអភិវឌ្ឍមូលដ្ឋាន
- បានសិក្សារៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត ការលុបចោល ការបង្រួម ការបំបែក និងការកែសម្រួលព្រំប្រទល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ
- បាន និងកំពុងរៀបចំកែសម្រួលសៀវភៅណែនាំស្តីពីការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ។

### ២.៣.១.១.៣. ទីក្រុងវៃឆ្លាត

សម្រាប់ការងារទីក្រុងឆ្លាតបានសម្រេចលទ្ធផលការងារមួយចំនួនរួមមានៈ(១)បានពង្រឹងសមត្ថភាពជំនាញ និងបទពិសោធដល់មន្ត្រីជំនាញលើការងារទីក្រុងឆ្លាត(២)បានដាក់បញ្ចូលក្រុងព្រះសីហនុនៃខេត្តព្រះសីហនុជាសមាជិកបណ្តាញទីក្រុងឆ្លាតអាស៊ាន។ ទន្ទឹមនេះ ក្រសួងមហាផ្ទៃ ក៏បាននិងកំពុងរៀបចំកែសម្រួលផែនទីបង្ហាញផ្លូវដើម្បីកំណត់ទស្សនទានអំពីការអភិវឌ្ឍទីក្រុងឆ្លាតសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំជាផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតថ្នាក់ជាតិ ២០២៤-២០៣៥។

### ២.៣.១.១.៤. ការគ្រប់គ្រងធនធានមនុស្សថ្នាក់ក្រោមជាតិ

ប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ដែលធានាដល់ការផ្តល់សិទ្ធិអំណាចកាន់តែច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះរួមមានៈ

- បាននិងកំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីមុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រៀមរៀបចំការបណ្តុះបណ្តាលដល់ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស

- រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំឱ្យមានលក្ខខណ្ឌការងារសម្រាប់មន្ត្រី បុគ្គលិកប្រចាំឆ្នាំនៅតាមអង្គភាពសាមីនីមួយៗរបស់ខ្លួន

- រដ្ឋបាលថ្នាក់ក្រោមជាតិបានពង្រឹងការគ្រប់គ្រងបុគ្គលិករបស់ខ្លួនតាមរយៈការចុះបញ្ជីវត្តមានប្រចាំថ្ងៃនៅតាមអង្គភាពនីមួយៗ ជាពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌបានចាប់ផ្តើមគ្រប់គ្រងបុគ្គលិកនានារបស់ខ្លួន ដែលបានផ្ទេរទៅឱ្យតាមរយៈការធ្វើសមាហរណកម្មការិយាល័យជំនាញនានា ទៅក្នុងរចនាសម្ព័ន្ធក្រុង ស្រុក ខណ្ឌបានល្អប្រសើរជាងមុន

- ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាប្រព័ន្ធគ្រប់គ្រងព័ត៌មានទិន្នន័យបុគ្គលិកសម្រាប់ដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការចូលនិវត្តន៍ត្រូវបាននិងកំពុងសិក្សារៀបចំដោយក្រសួងមុខងារសាធារណៈ

បច្ចុប្បន្នរដ្ឋបាលថ្នាក់ក្រោមជាតិមានបុគ្គលិកចំនួន ១០៣.២៨២នាក់ ក្នុងនោះ៖

- មន្ត្រីបុគ្គលិករដ្ឋបាលរាជធានី ខេត្តមានសរុបចំនួន **២៥.៧៥៣នាក់** ស្ត្រីមានចំនួន **១៣.២០០នាក់** (មន្ត្រីបុគ្គលិករដ្ឋបាលចំនួន **៣.២៩៥នាក់** ស្ត្រីចំនួន **១.០៣ នាក់** និងគ្រូពេទ្យមានចំនួន **២២.៤៥៨នាក់** ស្ត្រីមានចំនួន**១២.១៦៩នាក់**)
- មន្ត្រីបុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌមានសរុបចំនួន **៧៧.៥២៩នាក់** (មន្ត្រីបុគ្គលិករដ្ឋបាលចំនួន **១៧.៥២៩នាក់** ស្ត្រីមានចំនួន **៦.៦៤១នាក់** និងគ្រូបង្រៀនប្រមាណជាង **៦០.០០០នាក់**)។

បានពិនិត្យនិងកែសម្រួលផែនការយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ(២០២៤-២០២៨)ដែលបច្ចុប្បន្នមន្ត្រីជាស្ត្រីទទួលបានមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត(អភិបាល អភិបាលរង នាយក/នាយករងរដ្ឋបាល នាយក/នាយករងទីចាត់ការ និងប្រធាន/អនុប្រធានការិយាល័យ) មានចំនួន **៥៨៣នាក់** ស្មើនឹង**២៧,៤៦ %** និងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ (អភិបាល អភិបាលរង នាយក/នាយករងរដ្ឋបាល នាយក/នាយករងទីចាត់ការ និងប្រធាន/អនុប្រធានការិយាល័យ) មានចំនួន **១.៦៦៨នាក់** ស្មើនឹង **២៣,៣២%**។

### ២.៣.១.១.៥. វិមជ្ឈការហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានរដ្ឋបាល ធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃក្នុងការសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធជំរុញនិងពង្រឹងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចដឹកនាំ គ្រប់គ្រង និងអនុវត្តតួនាទី ភារកិច្ច មុខងារ ព្រមទាំងអាចចាត់ចែង និងប្រើប្រាស់ធនធាន រួមទាំងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវាដែលបានកំណត់ឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។

គម្រោងថវិកាចំណូលប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្តឆ្នាំ២០២៤ មានចំនួនសរុបប្រមាណ **២.៧១៣.៤៧០លានរៀល** សមមូលជាដុល្លារអាមេរិកសរុបប្រមាណ **៦៧៨លានដុល្លារ** មានការកើនឡើងចំនួន១,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៣ ក្នុងនោះ និងគម្រោងថវិកាចំណាយសរុបប្រមាណ **១.៥៣៩.១២០លានរៀល** សមមូលជាដុល្លារអាមេរិកចំនួនសរុបប្រមាណ **៣៨៥លានដុល្លារ** មានការថយចុះចំនួន ១,២២% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៣ ក្នុងនោះចំណាយសម្រាប់រដ្ឋបាលចំនួនសរុបប្រមាណ **៧២៥.២៥២លានរៀល** សមមូលជាដុល្លារអាមេរិកចំនួនសរុបប្រមាណ **១៨១លានដុល្លារ** ចំណាយបន្ទុកបុគ្គលិកសរុបប្រមាណ **២១១.៩៤១លានរៀល** សមមូលជាដុល្លារអាមេរិកសរុបប្រមាណ **៥៣លានដុល្លារ** ចំណាយសម្រាប់អភិវឌ្ឍន៍សរុបប្រមាណ **៦០១.៩២៧លានរៀល** សមមូលជាដុល្លារអាមេរិកសរុបប្រមាណ **១៥០លានដុល្លារ**។

ដោយឡែកការអនុវត្តមុខងារសុខាភិបាល៖ រដ្ឋបាលរាជធានី ខេត្ត ទទួលបានគម្រោងចំណាយសម្រាប់ការអនុវត្តការប្រគល់មុខងារសុខាភិបាលចំនួនសរុបប្រមាណ **៨៨៧.០១០លានរៀល** សមមូលជាដុល្លារអាម៉េរិកចំនួនសរុបប្រមាណ **២២២លានដុល្លារ**។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិសម្រាប់ការិយបរិច្ឆេទ២០២៣ សំដៅពង្រឹងការគ្រប់គ្រង និងការអនុវត្តថវិកា ក្រសួងមហាផ្ទៃបានណែនាំដល់រដ្ឋបាលខេត្តមួយចំនួនឱ្យលើកកម្ពស់ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការគ្រប់គ្រងបុគ្គលិក និងការអនុវត្តចំណូល-ចំណាយថវិកា។

**២.៣.១.១.៦. ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៤ ដែលទើបប្រកាសចូលកាន់តំណែងថ្មីត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ នៃអាណត្តិរបស់ខ្លួន ដើម្បីដាក់ចេញនូវចក្ខុវិស័យក្នុងការអភិវឌ្ឍមូលដ្ឋានប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាបន្ន។ ដើម្បីឱ្យការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០២៥-២០២៩) របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអាណត្តិទី៤ ប្រព្រឹត្តទៅដោយរលូនទាន់ពេលវេលាកំណត់ និងទទួលបានលទ្ធផលល្អប្រសើរ ក្រសួងមហាផ្ទៃបានធ្វើការរំលឹក និងណែនាំដល់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌចាត់ចែងអនុវត្តនូវកិច្ចការសំខាន់ៗដែលមានកំណត់នៅក្នុងសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ដោយកំណត់ក្របខ័ណ្ឌពេលវេលានៃការរៀបចំត្រឹមខែមិថុនាឆ្នាំ២០២៥ ដែលជាឆ្នាំទី១ នៃអាណត្តិរបស់ក្រុមប្រឹក្សា ។ ទន្ទឹមនេះ ក៏បានណែនាំដល់រដ្ឋបាលរាជធានីខេត្តឱ្យពង្រឹងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួនផងដែរ។

**២.៣.១.១.៧. ការសហការជាមួយក្រសួង ស្ថាប័ន និងការអន្តរាគមន៍ដល់រដ្ឋបាលរាជធានី ខេត្ត**

អគ្គនាយកដ្ឋានរដ្ឋបាល ជាសេនាធិការឱ្យក្រសួងមហាផ្ទៃ បានសហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធលើការងារមួយចំនួនមានដូចខាងក្រោម៖

- សេចក្តីព្រាងច្បាប់ស្តីពីភូមិបាលថ្មី
- សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម
- សេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសងខុសច្បាប់
- សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសន្តិសុខតាមបុរី
- សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលសមាសភាពនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីនីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយអាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋសម្រាប់គម្រោងវិនិយោគរាជធានី ខេត្ត
- សេចក្តីព្រាងប្រកាសអំពីការកំណត់បែបបទ នីតិវិធី និងវិធានក្នុងការគ្រប់គ្រងផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង
- សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំសម្រាប់ការបោះឆ្នោតលើកទី១ ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុងកំពង់សោមនៃខេត្តព្រះសីហនុ ឆ្នាំ២០២៥
- សេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការសិក្សាពេញមួយជីវិត
- សេចក្តីព្រាងកម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងបរិការណ៍សកលដែលមានភាពមិនប្រាកដប្រជាខ្ពស់ឆ្នាំ២០២៥-២០២៨
- សេចក្តីព្រាងកម្មវិធីពិសេសជំរុញការវិនិយោគខេត្តព្រះសីហនុ ឆ្នាំ២០២៤
- សេចក្តីព្រាងកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួន នៅភូមិភាគឦសាននៃប្រទេសកម្ពុជា

- សេចក្តីព្រាងរបាយការណ៍ផែនការមេអភិវឌ្ឍន៍បណ្តាខេត្តជាប់ឆ្នេរសមុទ្រកម្ពុជាជារបៀងសេដ្ឋកិច្ចពហុបំណង និងប្រទាក់ក្រឡា

- សេចក្តីព្រាងឯកសារទស្សនទានរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណងខេត្តជាប់ឆ្នេរសមុទ្រ(ជាគម្រោងសាងល្បង២០២៥-២០៣០)

- សេចក្តីព្រាងយុទ្ធសាស្ត្រជំរុញការអនុវត្តផែនការមេអភិវឌ្ឍន៍ខេត្តព្រះសីហនុ ជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុ-បំណងនិងអភិវឌ្ឍន៍បណ្តាខេត្តជាប់ឆ្នេរសមុទ្រកម្ពុជា ជារបៀងសេដ្ឋកិច្ចពហុបំណង និងប្រទាក់ក្រឡាឆ្នាំ២០២៥-២០៣០

- សេចក្តីព្រាងផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ២០២៤-២០២៨

- សេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីជំឡងមី២០២០-២០២៥

- សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិជំរុញចលនាភូមិមួយផលិតផលមួយរយៈពេល៥ឆ្នាំ លើកទី២ (២០២៤-២០២៨)

- សេចក្តីព្រាងរបាយការណ៍វាយតម្លៃការអនុវត្តរបស់កម្ពុជាឆ្នាំ២០២៤ (2024 Country Performance Assessment Report) របស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)

- ការផ្តល់ធាតុចូលលើការកំណត់សូចនាករ និងសូចនាករសមិទ្ធកម្មសម្រាប់វាស់វែង សកម្មភាពពាក់ព័ន្ធដែលបានដាក់ចេញនៅក្នុងគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧

- ប្រមូលទិន្នន័យ និងធ្វើបច្ចុប្បន្នភាពវឌ្ឍនភាពរបាយការណ៍ នៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាលផ្នែកឯកជនលើកទី១៩ ប្រចាំឆមាសទី២ ឆ្នាំ២០២៤

- ការពិគ្រោះយោបល់អំពីការធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ (រូបថតនិងស្នាមម្រាមដៃ) របស់អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបន្ថែមរយៈពេល៣០ (សាមសិប)ថ្ងៃ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅក្នុងឆ្នាំ២០២៥

- បំពេញកម្រងសំណួរ Questionnaire ក្នុងគម្រោងភាពរួចរាល់នៃធុរកិច្ច(Business Ready ឬ B-Ready) របស់ធនាគារពិភពលោក(WB)

- បំពេញកម្រងសំណួរព័ត៌មានស្តីពីការផលិតស្ថិតិតាមអង្គភាពស្ថិតិរបស់ប្រព័ន្ធជាតិកម្ពុជា ដើម្បីជាធាតុចូលសម្រាប់យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ឆ្នាំ២០២៤-២០២៨

- ការសិក្សាវិភាគលើគោលនយោបាយសេដ្ឋកិច្ចកំណែទម្រង់ពន្ធលើផលិតផលប៉ះពាល់ដល់សុខភាពគ្រឿងស្រវឹង ថ្នាំជក់ និងភេសជ្ជៈមានជាតិស្ករ

- ការសិក្សាសមិទ្ធិលទ្ធភាពស្តីពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនគរូបនីយកម្ម National Spatial Data Infrastructure (NSDI) នៅក្នុងប្រទេសកម្ពុជា

- ការផ្តល់ធាតុចូល និងជំនួយស្មារតីពាក់ព័ន្ធនឹងការដាក់ចេញនូវកំណែទម្រង់រដ្ឋបាល និងអភិបាលកិច្ចគោរពជូន

**សម្តេចធិបតីនាយករដ្ឋមន្ត្រី**

- ការផ្តល់ទិន្នន័យសម្រាប់ការរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ (IDP) ប្រចាំឆ្នាំ២០២៣

អគ្គនាយកដ្ឋានរដ្ឋបាល បានសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលក្នុងការអន្តរាគមន៍ទៅរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងការជួយគាំទ្រដល់រដ្ឋបាលរាជធានី ខេត្ត សរុបចំនួន **១៧៩ករណី** ដែលផ្តោតលើការងាររួមមាន៖ ការចាត់សមាសភាពចូលរួមក្នុងគណៈកម្មការ/ក្រុមការងារអន្តរក្រសួង ការបាក់ច្រាំងទន្លេ ការអញ្ជើញចូលរួមកិច្ចប្រជុំ ឬសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាល ការចុះអង្កេតស្រាវជ្រាវ ឬប្រមូលទិន្នន័យនៅមូលដ្ឋាន ការបង្កើត

រដ្ឋាករស្វ័យតដឹកជញ្ជូនសាធារណៈខេត្ត ការស្នើសុំផ្លាកលេខរដ្ឋ ការចាត់តំណាងមកទទួលយករថយន្តក្រុង ជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ការចុះបំពេញបេសកកម្មរបស់គណៈកម្មការរដ្ឋសភា និងព្រឹទ្ធសភា ការសម្របសម្រួលសន្តិសុខ និងសណ្តាប់ធ្នាប់ចំពោះការរៀបចំការបោះឆ្នោត ការធ្វើធម្មយាត្រា ការដង្ហែកង់ និងការរៀបចំព្រឹត្តិការណ៍នានា និងសម្របសម្រួលធ្លាក់គ្រោះរដ្ឋបាលជាដើម។

**២.៣.១.១.៨. ការផ្តល់គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

ក្នុងឆ្នាំ២០២៤ ក្រសួងមហាផ្ទៃបានលើកសំណើសុំទៅរាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់គោរមងារជាឧកញ៉ា ចំនួន **១៣រូប** និងផ្តល់គ្រឿងឥស្សរិយយស (មេដាយចម្រុះសរុបចំនួន **២.០១៨គ្រឿង** មេដាយស្ថាបនាជាតិសរុបចំនួន **៥១៥គ្រឿង** និងមេដាយការងារសរុបចំនួន **៤០៨គ្រឿង**) ដើម្បីសម្តែងនូវការដឹងគុណ និងលើកទឹកចិត្តដល់មន្ត្រីរាជការ និងសប្បុរសជននានាដែលបានចំណាយថវិកាផ្ទាល់ខ្លួនជួយកសាង និងអភិវឌ្ឍន៍ប្រទេសជាតិសរុប **១៧៦.៧៥៤.១៨១ដុល្លារអាមេរិក**។

**២.១.៣.១.១.៩. ការផ្ទេរមុខងារ និងការគាំទ្រការអនុវត្តមុខងារ**

ការផ្ទេរមុខងារ និងការគាំទ្រការអនុវត្តមុខងារ ដែលបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាកិច្ចការដ៏មានសារៈសំខាន់ និងអាទិភាព នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ក្នុងឆ្នាំ២០២៤នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានសហការរៀបចំ និងដាក់ចេញប្រកាសអន្តរក្រសួងចំនួន២ ក្នុងវិស័យសុខាភិបាលរវាងក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាលរួមមាន ១).ប្រកាសអន្តរក្រសួងស្តីពីការបង្កើតអង្គភាពសុខាភិបាល និង ២). ប្រកាសអន្តរក្រសួងស្តីពីការដំឡើងមន្ទីរពេទ្យបង្អែកកោះធំកម្រិត២ (CPA2) ទៅជាមន្ទីរពេទ្យតេជោសែនកោះធំកម្រិត៣ (CPA3) ។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាល បានសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការពិនិត្យ និងផ្តល់យោបល់លើលិខិតបទដ្ឋានមួយចំនួន រួមមាន៖

១).សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការអនុវត្តមុខងារផ្តល់សេវាអភិវឌ្ឍន៍ក្នុងវិស័យពាណិជ្ជកម្មនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

២).សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីនីតិវិធីពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីនគរូបនីយកម្មនិងសំណង់ និង

៣).សេចក្តីប្រកាសអន្តរក្រសួងស្តីពីការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាមសំណល់រឹង ទីប្រជុំជនសម្រាប់រដ្ឋបាលក្រុង និងរដ្ឋបាលស្រុក និងលិខិតបទដ្ឋានមួយចំនួនទៀត ដូចជាច្បាប់ស្តីពីប្រព័ន្ធទឹកកខ្វក់ដែលទើបនឹងដាក់ចេញនាពេលថ្មីៗនេះ ។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋានគ.ជ.អ.ប. និងក្រសួងស្ថាប័ន ដើម្បីគាំទ្រនិងតាមដានការអនុវត្តមុខងារដែលបានផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិពិសេសគឺ ការចូលរួមដឹកនាំការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាមសំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា ក្រោមហិរញ្ញប្បទានពីធនាគារពិភពលោក ដែលរួមចំណែកលើកកម្ពស់ការអនុវត្តមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន និងការគ្រប់គ្រងទីលានទុកដាក់សំរាមប្រកបដោយស្តង់ដាអនាម័យ។

**២.៣.២. ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន**

២.៣.២.១. ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ

ក. <u>អង្គភាពច្រកចេញចូលតែមួយ</u>

ក្នុងឆ្នាំ២០២៤ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តបានផ្តល់សេវារដ្ឋបាលសរុបចំនួន **៨៨៥.១១៧សេវា** បើប្រៀបធៀបនឹងឆ្នាំ២០២៣មានការកើនឡើងចំនួន **២៥៩.៣៨៨សេវា** ស្មើនឹងចំនួន **១៧,១៦%** ក្នុងនោះចំនួន

សេវាដែលបានផ្តល់ក្នុងវិស័យទាំង១៤ឃើញថា**វិស័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់** បានផ្តល់សេវាចំនួន៣០៨.២៣៨សេវា (ស្មើនឹង៣៤,៨២%) បន្ទាប់មកគឺ **ការងាររដ្ឋបាល** បានផ្តល់សេវាចំនួន២២០.០៤១សេវា (ស្មើនឹងចំនួន ២៤,៨៦%) ចំពោះវិស័យដែលបានផ្តល់សេវាតិចជាងគេគឺ **វិស័យពាណិជ្ជកម្ម** ចំនួន ១០សេវា(ស្មើនឹងចំនួន ០,០០១%)។ ទន្ទឹមនេះ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តទទួលបានចំណូលពីការផ្តល់សេវារដ្ឋបាលសរុបចំនួន ១៣០.៣៦៩.០៦៣.០២១រៀល (ស្មើនឹងចំនួន ៣២.៥៩២.២៦៥,៧៥ដុល្លារអាមេរិក) បើប្រៀបធៀបនឹងឆ្នាំ២០២៣មានការកើនឡើងចំនួន ៣៩.៤៧២.១៣២.៤៧៥រៀល ស្មើនឹង១៧,៨៤% ក្នុងនោះចំណូលដែលទទួលបានក្នុងវិស័យទាំង១៤ ឃើញថា**វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**ទទួលបានចំណូលខ្ពស់ជាងគេគឺចំនួន ៩៦.៥៤៥.៥៩៨.៨៣១រៀល (ស្មើនឹងចំនួន ៧៤,០៦%) បន្ទាប់មក **វិស័យសាធារណៈការ និងដឹកជញ្ជូន** ទទួលបានចំណូលចំនួន ១៣.៥៩៤.៣១០.៥៥០រៀល (ស្មើនឹង១០,៤៣%) ចំពោះវិស័យដែលទទួលបានចំណូលតិចជាងគេគឺ **វិស័យពាណិជ្ជកម្ម**ចំនួន ២.០០០.០០រៀល (**ស្មើនឹង**០,០០២%)។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការប្រព័ន្ធទូទាត់វិក្កយបត្រ (PaymentHub) នៅគ្រប់អង្គភាពច្រកចេញចូលតែមួយ និងបានពង្រីកការអនុវត្តសាកល្បងកម្មវិធីព័ត៌មានវិទ្យាសម្រាប់ទទួលពាក្យស្នើសុំ និងផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញនៅរដ្ឋបាលរាជធានី ខេត្តចំនួន១២ ។ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានរៀបចំកិច្ចប្រជុំ ការបណ្តុះបណ្តាល និងបានចាត់តាំងក្រុមការងារចុះគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការផ្តល់សេវារដ្ឋបាល តាមអង្គភាពច្រកចេញចូលតែមួយ។

ខ. **ការិយាល័យច្រកចេញចូលតែមួយ**

ក្នុងឆ្នាំ២០២៤នេះ ការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានផ្តល់សេវាសរុបចំនួន ៤.៣២១.២៣១សេវា ក្នុងនោះបើប្រៀបធៀបចំនួនសេវាវិស័យទាំង១៧ ឃើញថា **ការងារអត្រានុកូលដ្ឋាន** បានផ្តល់សេវាបានច្រើនជាងគេគឺចំនួន ២.៤២១.៧៥០សេវា(ស្មើនឹង៥៦,០៤%)បន្ទាប់មក **ការងារនីត្យានុកូលកម្ម** បានផ្តល់សេវាចំនួន ១.៦៧៦.៦២៣សេវា(ស្មើនឹង៣៨,៨០%)។ ចំពោះវិស័យដែលបានផ្តល់សេវាតិចជាងគេគឺ **វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**បានផ្តល់សេវាចំនួន ០៤សេវា(**ស្មើនឹង**០,០០១%)។ រយៈពេលដូចគ្នានេះដែរការិយាល័យច្រកចេញចូលតែមួយទទួលបានចំណូលសរុបចំនួន ១១.៣៣៩.៤៧០.៦០៤រៀល (**ស្មើនឹង**២.៨៣៤. ៨៦៧,៦៥ដុល្លារអាមេរិក) ក្នុងនោះបើប្រៀបធៀបចំណូលដែលទទួលបានក្នុងវិស័យទាំង ១៧ ឃើញថា **វិស័យសុរិយោដី** ទទួលបានចំណូលខ្ពស់ជាងគេគឺចំនួន ២.៩៩៩.៣៦៤.០០០រៀល (ស្មើនឹង២៦,៤៥%) បន្ទាប់មកវិស័យសំណង់ទទួលបានចំណូលចំនួន ២.៤៣១.៥៥០.៦០០រៀល (ស្មើនឹង ២១,៤៤%) ចំពោះវិស័យទទួលបានចំណូលតិចជាងគេគឺវិស័យការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈទទួលបានចំណូលចំនួន ៥០០.០០០រៀល (ស្មើនឹង ០,០០៤%) និង វិស័យដែលមិនបានទទួលចំណូលគឺ **វិស័យធម្មការ និងសាសនា ការងារអត្រានុកូលដ្ឋាន** និង**វិស័យបរិស្ថាន**។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានរដ្ឋបាលបានដាក់ឱ្យអនុវត្តសាកល្បងការស្នើសុំសេវារដ្ឋបាលតាមប្រព័ន្ធអនឡាញលើប្រភេទសេវាចំនួន៩ នៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុកគោលដៅចំនួន៩ បានធ្វើបច្ចុប្បន្នភាពកម្រងសេវារដ្ឋបាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងបានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ របស់ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ និងការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ។

គ. **ការសម្រុះសម្រួលដោះស្រាយបណ្តឹង**

➤ **ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**

ក្នុងឆ្នាំ២០២៤នេះ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តបានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋសរុបចំនួន **១៦០២ករណី** ដែលក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន **៤៤០ករណី** (បញ្ចប់ការដោះស្រាយចំនួន **២២៩ករណី** និងកំពុងដោះស្រាយចំនួន**២១១ករណី**) បណ្តឹងក្រៅសមត្ថកិច្ចចំនួន**៣២៦ករណី** និងព័ត៌មានផ្សេងៗចំនួន **៨៣៦ករណី** (ការសរសើរចំនួន **១៧១ករណី** សំណើនិងសំណូមពរចំនួន **២៥២ករណី** និងការសាកសួរព័ត៌មានចំនួន **៤១៣ករណី**)។ ពាក់ព័ន្ធនឹងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត អគ្គនាយកដ្ឋានរដ្ឋបាលបាននិងកំពុងពិនិត្យ និងកែសម្រួលលើកទី១ សៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងគ្រោងដាក់ចេញនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៥ខាងមុខ និងពិនិត្យកែសម្រួលការធ្វើសន្ទានកម្មរវាងប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តឹងនិងព័ត៌មានផ្សេងៗរបស់ការិយាល័យប្រជាពលរដ្ឋជាមួយកម្មវិធីទូរសព្ទដៃមតិយើង និងបានគាំទ្រដំណើរការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត និងប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌគោលដៅមួយចំនួន ដែលចប់អាណត្តិការងារ។ បន្ថែមពីនេះក៏បានរៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងការប្រកាសជ័យលាភីការិយាល័យ ប្រជាពលរដ្ឋឆ្នើមប្រចាំឆ្នាំ២០២៣ ព្រមទាំងបានដំឡើងម៉ាស៊ីនមេ (Server) សម្រាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តឹង និងព័ត៌មានផ្សេងៗរបស់ការិយាល័យប្រជាពលរដ្ឋ និងកម្មវិធីទូរសព្ទដៃ "មតិយើង" និងវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តឹងនិងព័ត៌មានផ្សេងៗរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងកម្មវិធីទូរសព្ទដៃ"មតិយើង"។

- **ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ**

នៅក្នុងឆ្នាំ២០២៤នេះ ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌបានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋបានចំនួន **២៧.១៤១ករណី** ក្នុងនោះបណ្តឹង និងព័ត៌មានផ្សេងៗដែលបានធ្វើការសម្រាំងបានចំនួន **២១.៩៦៩ករណី**។ ចំពោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន **៤០០ករណី** (បញ្ចប់ការដោះស្រាយចំនួន **២៥៦ករណី** និងកំពុងដោះស្រាយចំនួន **១៤៤ករណី**) បណ្តឹងក្រៅសមត្ថកិច្ចចំនួន **២០២ករណី** ព័ត៌មានផ្សេងៗសរុបចំនួន **២១.៣៦៧ករណី** (ការសរសើរចំនួន **៧៦៣ករណី** សំណើនិងសំណូមពរចំនួន **៣.៨១៦ករណី** និងការសាកសួរព័ត៌មានចំនួន **១៦.៧៨៨ករណី**)។ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពដល់ប្រធាន និងជំនួយការការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌផងដែរ។

### ២.៣.២.២. ការផ្តល់សេវាសង្គម

ការផ្តល់សេវាសង្គម គឺជាផ្នែកមួយនៃសេវាសាធារណៈដ៏មានសារៈសំខាន់សម្រាប់ផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដើម្បីជួយសម្រាលការលំបាកដល់ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះ ដូចជា**ស្ត្រី កុមារ ជនចាស់ជរា ជនក្រីក្រ ជនមានពិការភាព** និង**ជនជាតិដើមភាគតិច**ជាដើម។

ចាប់តាំងពីឆ្នាំ២០១៩ ក្រសួងមហាផ្ទៃបានសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំកំណត់ឱ្យមានបញ្ជីជម្រើសមុខសញ្ញាចំណាយ ដោយភ្ជាប់ជាមួយមាតិកាថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចសម្រាប់ចំណាយសេវាសង្គមរបស់រដ្ឋបាលរាជធានី ខេត្ត និងបានណែនាំឱ្យមានការវិភាជន៍៥% នៃថវិកាគុណប្រយោជន៍សម្រាប់ចំណាយលើគម្រោងសេវាសង្គម។ ក្នុងឆ្នាំ២០២៣ ក្រសួងមហាផ្ទៃបានកំណត់សារជាថ្មីឱ្យមានការវិភាជន៍ថវិកាក្នុងកម្រិតយ៉ាងតិច១០%ដោយត្រូវអនុវត្តចាប់ពីឆ្នាំ២០២៤នេះទៅ។ ជាក់ស្តែងក្នុងឆ្នាំ២០២៤នេះ តាមរយៈលទ្ធផលនៃសិក្ខាសាលាស្តីពីការរៀបចំគម្រោងសេវាសង្គមរបស់រដ្ឋបាលរាជធានី ខេត្តឆ្នាំ២០២៤ បានបង្ហាញថារដ្ឋបាលរាជធានី

ខេត្ត បានផ្ដល់សេវាសង្គមតាមរយៈសកម្មភាព និងគម្រោងនានាមានចំនួនសរុប **៣១១គម្រោង** ស្មើនឹងទឹកប្រាក់អនុវត្តសរុប **២០៨.៤៦០លានរៀល** ដោយគិតជាមធ្យមស្មើនឹង **២១,១៦%** ធៀបនឹងថវិកាអភិវឌ្ឍន៍ស្មើនឹង **៧,៥៦%** ធៀបនឹងថវិកាសរុបប្រចាំឆ្នាំ។ ទន្ទឹមនេះរដ្ឋបាលរាជធានី ខេត្តបានគ្រោងការផ្ដល់សេវាសង្គមតាមរយៈការអនុវត្តគម្រោងសកម្មភាពសេវាសង្គមមានចំនួនសរុប **៣៣៥គម្រោង** ស្មើនឹងទឹកប្រាក់ **១៤៧.៨៤៣លានរៀល** ដោយគិតជាមធ្យមស្មើនឹង **១៥,១៦%** ធៀបនឹងថវិកាអភិវឌ្ឍន៍ ស្មើនឹង **៧,២៣%** ធៀបនឹងគម្រោងថវិកាសរុបប្រចាំឆ្នាំ២០២៥។

ជាមួយគ្នានេះចាប់តាំងពីឆ្នាំ២០២១កន្លងមកនេះ ក្រសួងមហាផ្ទៃបានដាក់ឱ្យអនុវត្តនូវកម្មវិធីពានរង្វាន់សម្រាប់ការផ្ដល់សេវាសង្គម នៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណងជំរុញ និងលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានខិតខំយកចិត្តទុកដាក់រៀបចំ និងអនុវត្តការងារសេវាសង្គមប្រកបដោយគុណភាព ក្នុងការជួយគាំពារប្រជាជននៅមូលដ្ឋានរបស់ខ្លួន។ ក្នុងឆ្នាំ២០២៤នេះ បានសហការរៀបចំកែសម្រួលកម្មវិធីពានរង្វាន់សេវាសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលដៅពង្រីកវិសាលភាពលើការអនុវត្តនៅគ្រប់រាជធានី ខេត្តទូទាំងប្រទេស និងសមស្របតាមការប្រែប្រួលនូវសភាពការថ្មីៗ រួមមានគោលនយោបាយរបស់រាជរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្ត និងការប្រែប្រួលស្ថានភាពសេដ្ឋកិច្ចសង្គមជាដើម។ ទន្ទឹមនេះផ្អែកតាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃបានកំណត់ឱ្យមានការដាក់បញ្ចូលសូចនាករវាយតម្លៃថ្មីមួយគឺការផ្ដល់សេវាតាមរយៈអង្គភាព ការិយាល័យ និងយន្តការច្រកចេញចូលតែមួយ។

### ២.៣.២.៣. ការរៀបចំ និងការអនុវត្តគម្រោង

ក្នុងឆ្នាំ២០២៤នេះ អគ្គនាយកដ្ឋានបានចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផលនៃការអនុវត្តគម្រោងប្រចាំឆ្នាំ២០២៣ នៅគ្រប់រដ្ឋបាលរាជធានី ខេត្តចំនួន **៤៨០គម្រោង** មានទឹកប្រាក់សរុប **២.២៣៨.៨១២លានរៀល** ជាគម្រោងហេដ្ឋារចនាសម្ព័ន្ធមានដូចជា៖ ផ្លូវ ស្ពាន អគាររដ្ឋបាល សាលប្រជុំ អគារអង្គភាពច្រកចេញចូលតែមួយ អគារការិយាល័យច្រកចេញចូលតែមួយ អគារសាលាឃុំ សង្កាត់ សួនច្បារសាធារណៈ បណ្ដាញអគ្គិសនី បណ្ដាញលូបង្ហូរទឹក អគារសិក្សា សាលាមត្តេយ្យសិក្សាសហគមន៍ និងសំណង់សិល្បការផ្សេងៗជាច្រើនទៀត។ល។ ការចុះត្រួតពិនិត្យ និងវាយតម្លៃនេះ ដើម្បីពិនិត្យចំណុចខ្វះខាត និងណែនាំឱ្យកែតម្រូវជាពិសេសធានាឱ្យការអនុវត្តគម្រោងមានគុណភាព អនុវត្តទៅតាមគោលការណ៍ណែនាំ ពង្រឹងការអនុវត្តគម្រោង និងពិនិត្យលើបញ្ហាដែលកើតមានឡើងដើម្បីដោះស្រាយឱ្យបានសមស្រប។

ជាមួយគ្នានេះ ក៏បានពិនិត្យ និងផ្ដល់អនុលោមភាពគម្រោងអភិវឌ្ឍន៍ដោយប្រើប្រាស់ថវិកាគុណប្រយោជន៍ឆ្នាំ២០២៤របស់រដ្ឋបាលរាជធានី ខេត្តសរុបចំនួន **២២០ម្រោង** មានទឹកប្រាក់សរុបចំនួន**៤៧៦.៤៩៥.៨៧០.៣០០រៀល (បួនរយចិតសិបប្រាំមួយប៊ីលានបួនរយកៅសិបប្រាំលានប្រាំបីរយចិតសិបពាន់បីរយរៀលគត់)** សមមូលជាដុល្លារអាម៉េរិកសរុបប្រមាណ**១១៩លានដុល្លារ** ដែលភាគច្រើនជាគម្រោងស្ថាបនា និងជួសជុលហេដ្ឋារចនាសម្ព័ន្ធដូចជា៖ ផ្លូវថ្នល់ អគាររដ្ឋបាល អគាររដ្ឋបាលឃុំ សង្កាត់ អគារសិក្សា បណ្ដាញអគ្គិសនី សួនច្បារសាធារណៈ ប្រព័ន្ធលូបង្ហូរទឹក ស្ថានីយបូមទឹក ច្រាំងទន្លេ ស្ពារប្រឡាយដោះទឹក ភ្លើងសញ្ញាចរាចរ គំនូសចរាចរណ៍ និងសំណង់សិល្បការនានា។ល។ គោលបំណង សំខាន់នៃការផ្ដល់អនុលោមភាពលើគម្រោងអភិវឌ្ឍន៍រាជធានី ខេត្តគឺដើម្បីធានាថា គម្រោងទាំងនោះមានសង្គតិភាពជាមួយផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលរាជធានី ខេត្តដោយបានរួមចំណែកឆ្លើយតបតម្រូវការអាទិភាពនានានៅក្នុងរាជធានី ខេត្តមានលក្ខណៈបច្ចេកទេសច្បាស់លាស់ដែលធានាបាននូវគុណភាព និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ ជាពិសេសអាចជៀសវាងបាននូវការកេងបន្លំថវិកាជាតិ

ខេត្ត បានផ្តល់សេវាសង្គមតាមរយៈសកម្មភាព និងគម្រោងនានាមានចំនួនសរុប **៣១១គម្រោង** ស្មើនឹងទឹកប្រាក់អនុវត្តសរុប **២០៨.៤៦០លានរៀល** ដោយគិតជាមធ្យមស្មើនឹង **២១,១៦%** ធៀបនឹងថវិកាអភិវឌ្ឍន៍ស្មើនឹង **៧,៥៦%** ធៀបនឹងថវិកាសរុបប្រចាំឆ្នាំ។ ទន្ទឹមនេះរដ្ឋបាលរាជធានី ខេត្តបានគ្រោងការផ្តល់សេវាសង្គមតាមរយៈការអនុវត្តគម្រោងសកម្មភាពសេវាសង្គមមានចំនួនសរុប **៣៣៥គម្រោង** ស្មើនឹងទឹកប្រាក់ **១៤៧.៨៤៣លានរៀល** ដោយគិតជាមធ្យមស្មើនឹង **១៥,១៦%** ធៀបនឹងថវិកាអភិវឌ្ឍន៍ ស្មើនឹង **៧,២៣%** ធៀបនឹងគម្រោងថវិកាសរុបប្រចាំឆ្នាំ២០២៥។

ជាមួយគ្នានេះចាប់តាំងពីឆ្នាំ២០២១កន្លងមកនេះ ក្រសួងមហាផ្ទៃបានដាក់ឱ្យអនុវត្តនូវកម្មវិធីពានរង្វាន់សម្រាប់ការផ្តល់សេវាសង្គម នៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណងជំរុញ និងលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានខិតខំយកចិត្តទុកដាក់រៀបចំ និងអនុវត្តការងារសេវាសង្គមប្រកបដោយគុណភាព ក្នុងការជួយគាំពារប្រជាជននៅមូលដ្ឋានរបស់ខ្លួន។ ក្នុងឆ្នាំ២០២៤នេះ បានសហការរៀបចំកែសម្រួលកម្មវិធីពានរង្វាន់សេវាសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលដៅពង្រីកវិសាលភាពលើការអនុវត្តនៅគ្រប់រាជធានី ខេត្តទូទាំងប្រទេស និងសមស្របតាមការប្រែប្រួលនូវសភាពការថ្មីៗ រួមមានគោលនយោបាយរបស់រាជរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្ត និងការប្រែប្រួលស្ថានភាពសេដ្ឋកិច្ចសង្គមជាដើម។ ទន្ទឹមនេះផ្អែកតាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃបានកំណត់ឱ្យមានការដាក់បញ្ចូលសូចនាករវាយតម្លៃថ្មីមួយគឺការផ្តល់សេវាតាមរយៈអង្គភាព ការិយាល័យ និងយន្តការច្រកចេញចូលតែមួយ។

### ២.៣.២.៣. ការរៀបចំ និងការអនុវត្តគម្រោង

ក្នុងឆ្នាំ២០២៤នេះ អគ្គនាយកដ្ឋានបានចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផលនៃការអនុវត្តគម្រោងប្រចាំឆ្នាំ២០២៣ នៅគ្រប់រដ្ឋបាលរាជធានី ខេត្តចំនួន **៤៨០គម្រោង** មានទឹកប្រាក់សរុប **២.២៣៨.៨១២លានរៀល** ជាគម្រោងហេដ្ឋារចនាសម្ព័ន្ធមានដូចជា៖ ផ្លូវ ស្ពាន អគាររដ្ឋបាល សាលប្រជុំ អគារអង្គភាពច្រកចេញចូលតែមួយ អគារការិយាល័យច្រកចេញចូលតែមួយ អគារសាលាឃុំ សង្កាត់ សួនច្បារសាធារណៈ បណ្តាញអគ្គិសនី បណ្តាញលូបង្ហូរទឹក អគារសិក្សា សាលាមត្តេយ្យសិក្សាសហគមន៍ និងសំណង់សិល្បការផ្សេងៗជាច្រើនទៀត។ល។ ការចុះត្រួតពិនិត្យ និងវាយតម្លៃនេះ ដើម្បីពិនិត្យចំណុចខ្វះខាត និងណែនាំឱ្យកែតម្រូវជាពិសេសធានាឱ្យការអនុវត្តគម្រោងមានគុណភាព អនុវត្តទៅតាមគោលការណ៍ណែនាំ ពង្រឹងការអនុវត្តគម្រោង និងពិនិត្យលើបញ្ហាដែលកើតមានឡើងដើម្បីដោះស្រាយឱ្យបានសមស្រប។

ជាមួយគ្នានេះ ក៏បានពិនិត្យ និងផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍន៍ដោយប្រើប្រាស់ថវិកាគុណប្រយោជន៍ឆ្នាំ២០២៤របស់រដ្ឋបាលរាជធានី ខេត្តសរុបចំនួន **២២០ម្រោង** មានទឹកប្រាក់សរុបចំនួន**៤៧៦.៤៩៥.៨៧០.៣០០រៀល (បួនរយចិតសិបប្រាំមួយប៊ីលានបួនរយកៅសិបប្រាំលានប្រាំបីរយចិតសិបពាន់បីរយរៀលគត់)** សមមូលជាដុល្លារអាម៉េរិកសរុបប្រមាណ**១១៩លានដុល្លារ** ដែលភាគច្រើនជាគម្រោងស្ថាបនា និងជួសជុលហេដ្ឋារចនាសម្ព័ន្ធដូចជា៖ ផ្លូវថ្នល់ អគាររដ្ឋបាល អគាររដ្ឋបាលឃុំ សង្កាត់ អគារសិក្សា បណ្តាញអគ្គិសនី សួនច្បារសាធារណៈ ប្រព័ន្ធលូបង្ហូរទឹក ស្ថានីយបូមទឹក ច្រាំងទន្លេ ស្ពានប្រឡាយដោះទឹក ភ្លើងសញ្ញាចរាចរ គំនូសចរាចរណ៍ និងសំណង់សិល្បការនានា។ល។ គោលបំណង សំខាន់នៃការផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍន៍រាជធានី ខេត្តគឺដើម្បីធានាថា គម្រោងទាំងនោះមានសង្គតិភាពជាមួយផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលរាជធានី ខេត្ត ដោយបានរួមចំណែកឆ្លើយតបតម្រូវការអាទិភាពនានានៅក្នុងរាជធានី ខេត្តមានលក្ខណៈបច្ចេកទេសច្បាស់លាស់ ដែលធានាបាននូវគុណភាព និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ ជាពិសេសអាចជៀសវាងបាននូវការកេងបន្លំថវិកាជាតិ

នៅក្នុងការចំណាយលើការអនុវត្តគម្រោង។ អគ្គនាយកដ្ឋានក៏បានធ្វើលិខិតក្នុងនាមក្រសួងមហាផ្ទៃក្រើនរំលឹកដល់រដ្ឋបាលខេត្តចំនួន៧ ឱ្យយកចិត្តទុកដាក់សិក្សា និងរៀបចំសំណើគម្រោងដើម្បីស្នើសុំអនុលោមភាពពីក្រសួងមហាផ្ទៃ និងបានណែនាំដល់រដ្ឋបាលរាជធានី ខេត្ត ឱ្យពិនិត្យលទ្ធភាពបំពាក់កាមេរ៉ាសុវត្ថិភាពតាមទីសាធារណៈ ពិសេសតាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ ដោយប្រើប្រាស់កញ្ចប់ថវិកាប្រចាំឆ្នាំរបស់ខ្លួន។

មួយវិញទៀត អគ្គនាយកដ្ឋានរដ្ឋបាលបាននិងកំពុងរៀបចំប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើការតាមដានការរៀបចំ និងអនុវត្តគម្រោងនៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

### ២.៣.៣. ការពង្រឹង និងការពង្រីកកិច្ចសហប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

#### ២.៣.៣.១. កិច្ចសហប្រតិបត្តិការខេត្តជាប់ព្រំដែន

ក្នុងឆ្នាំ២០២៤ បានសម្របសម្រួលរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៨ ក្រោមអធិបតីភាពសហប្រធាន **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា** និង**ឯកឧត្តម អនុទីន ឆានវីរៈគូល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រថៃ** នាថ្ងៃទី២២-២៤ ខែតុលា ឆ្នាំ២០២៤ ដើម្បីជំរុញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អរវាងខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជំរុញការផ្លាស់ប្តូរពាណិជ្ជកម្មឆ្លងដែន ការថែរក្សាការពារសន្តិសុខសណ្តាប់ធ្នាប់ និងស្ថិរភាពនៅតំបន់ព្រំដែនកម្ពុជា-ថៃ។

ទន្ទឹមនេះ ក្រសួងមហាផ្ទៃបានតាមដាន ពិនិត្យ សម្របសម្រួល និងដោះស្រាយលើការងារសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ពិនិត្យនីត្យានុកូលភាពលើកំណត់ហេតុនៃកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការខេត្តជាប់ព្រំដែនកម្ពុជានិងខេត្តនៃប្រទេសជិតខាង
- ណែនាំដល់រដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាងឱ្យយកចិត្តទុកដាក់ក្នុងការថែរក្សាការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ នៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែន
- ចូលរួមសហការក្នុងការពិនិត្យ និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់និងព្រែកជ្រៃធំតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដោយភាគីទាំងពីរបានចុះហត្ថលេខាលើកំណត់ហេតុកិច្ចប្រជុំលើកទី២ របស់ក្រុមការងារចម្រុះកម្ពុជា-វៀតណាម និងវៀតណាម-កម្ពុជាស្តីពីការដោះស្រាយបញ្ហាបាក់ស្រុតច្រាំងទន្លេបាសាក់-ទន្លេហ៊្សូវ និងព្រែកជ្រៃធំ ព្រែកបិញយី កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤។

#### ២.៣.៣.២. ការចងសម្ព័ន្ធមេត្រីភាពជាមួយខេត្ត ក្រុងនៃបណ្តាប្រទេសនានា

ក្នុងឆ្នាំ២០២៤នេះ ក្រោមការសម្របសម្រួលពីក្រសួងមហាផ្ទៃ មានរដ្ឋបាលរាជធានី ខេត្ត ក្រុងចំនួន ៩ បានទទួលគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលលើការចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយខេត្ត ក្រុង នៃបណ្តាប្រទេសជាមិត្តមានចំនួន ១៤ អនុស្សរណៈ ក្នុងនោះរួមមាន រដ្ឋបាលរាជធានីភ្នំពេញមានចំនួន ៤ អនុស្សរណៈ ខេត្តសៀមរាបមានចំនួន ១ អនុស្សរណៈ ខេត្តបន្ទាយមានជ័យមានចំនួន ២ អនុស្សរណៈ ខេត្តកំពង់ធំមានចំនួន ១ អនុស្សរណៈ ខេត្តកែបមានចំនួន ២ អនុស្សរណៈ ក្រុងស្វាយរៀងមានចំនួន ១ អនុស្សរណៈ ខេត្តកំពង់ស្ពឺមានចំនួន ១ អនុស្សរណៈ ខេត្តកណ្តាលមានចំនួន ១ អនុស្សរណៈ និងខេត្តបាត់ដំបងចំនួន ១ អនុស្សរណៈ ប៉ុន្តែរហូតមកដល់ពេលបច្ចុប្បន្ននេះ កិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នាជាមួយរាជធានី ខេត្ត ក្រុង នៃបណ្តាប្រទេសជាមិត្តចំនួន ៣ ត្រូវបានចុះហត្ថលេខារួមមាន៖ រដ្ឋបាលរាជធានីភ្នំពេញចំនួន ១ កិច្ចព្រមព្រៀង ខេត្តកំពង់ធំចំនួន ១

កិច្ចព្រមព្រៀង និងខេត្តកំពង់ស្ពឺចំនួន១កិច្ចព្រមព្រៀង(ដូចមានឧបសម្ព័ន្ធភ្ជាប់)។ ទន្ទឹមនេះ កិច្ចព្រមព្រៀងចំនួន ១ កំពុងបន្តការរៀបចំស្នើសុំគោលការណ៍សម្រេចពីរាជរដ្ឋាភិបាល។

តាមរយៈការបង្កើតចំណងសម្ព័ន្ធមេត្រីភាព និងការផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមករាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានលើកកម្ពស់ទំនាក់ទំនងទ្វេភាគីជាមួយបណ្តាប្រទេសជាមិត្តនិងជំរុញកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗជាច្រើនរួមមាន៖ វិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគ អប់រំ សុខាភិបាល ដឹកជញ្ជូន កសិកម្ម អភិវឌ្ឍន៍ជនបទ វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ការថែរក្សាបរិស្ថានជាដើម ដែលបានរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅមូលដ្ឋានយ៉ាងច្រើនគួរឱ្យកត់សម្គាល់។ ទន្ទឹមនេះការផ្លាស់ប្តូរទស្សនកិច្ចដើម្បីចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងទស្សនកិច្ចសិក្សានានាបានអនុញ្ញាតឱ្យរដ្ឋបាលរាជធានី ខេត្តទទួលបាននូវចំណេះដឹងថ្មីៗ និងបទពិសោធល្អៗក្នុងការគ្រប់គ្រង ដឹកនាំ និងកសាងមូលដ្ឋានរបស់ខ្លួនប្រែក្លាយជាទីក្រុងទីប្រជុំជន គួរឱ្យរស់នៅ មានផាសុកភាព មានមេត្រីភាពជាមួយបរិស្ថាន និងលើកគុណភាពជីវិតរបស់ប្រជាជន ដែលបានឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) របស់អង្គការសហប្រជាជាតិ។

**២.៣.៣.៣. កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល**

ក្នុងឆ្នាំ២០២៤ អគ្គនាយកដ្ឋាន បាននិងកំពុងសហការជាមួយយូនីសេហ្វនៅក្នុងការអនុវត្តគម្រោងចំនួន ២ គឺគម្រោងលើកកម្ពស់ការអនុវត្តសេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងគម្រោងកិច្ចការពារ។ ក្រៅពីនេះ អគ្គនាយកដ្ឋានក៏បានសហការជាមួយអង្គការ CHAI ( Clinton Health Access Initiative) ក្នុងការអនុវត្តគម្រោងទប់ស្កាត់ជំងឺមិនឆ្លង និងអង្គការក្លែនអន្តរជាតិក្នុងការអនុវត្តគម្រោងលើកកម្ពស់ការគាំពារនិងអភិវឌ្ឍន៍កុមារតូច និងលើកកម្ពស់អនាម័យនៅមូលដ្ឋានគាំទ្រដោយអង្គការក្លែនអន្តរជាតិកម្ពុជា។ គម្រោងទាំងនេះ គឺសុទ្ធតែជាគម្រោងដែលរួមចំណែកនៅក្នុងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋដែលងាយរងគ្រោះ ដែលរួមមាន៖ ប្រជាពលរដ្ឋក្រីក្រ ចាស់ជរា ស្ត្រី កុមារ ជនមានពិការភាពជាដើម។ ការអនុវត្តគម្រោងដូចបានរៀបរាប់ខាងលើនេះពិតជាបានរួមចំណែកយ៉ាងខ្លាំងនៅក្នុងការអភិវឌ្ឍមូលធនមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលនឹងរួមចំណែកក្នុងការសម្រេចបាននូវគោលដៅជ្រុងមួយនៃបញ្ចកោណយុទ្ធសាស្ត្ររបស់ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧នៃរដ្ឋសភា។

**២.៣.៣.៤. ការគ្រប់គ្រងច្រកទ្វារព្រំដែន**

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនសរុប **៧៤ច្រក** ក្នុងនោះរួមមាន៖ ច្រកទ្វារព្រំដែនអន្តរជាតិចំនួន **២៦ច្រក** ច្រកទ្វារព្រំដែនទ្វេភាគីចំនួន **១៣ច្រក** ច្រកទ្វារតំបន់ព្រំដែនចំនួន **២៦ច្រក** និងច្រកទ្វារកំពង់ផែសមុទ្រចំនួន **៩ច្រក**។

បច្ចុប្បន្ននេះ អគ្គនាយកដ្ឋានបានពិនិត្យ និងបញ្ចប់ការពិភាក្សាផ្ទៃក្នុង ព្រមទាំងបានកែសម្រួលលើខ្លឹមសារនៃសេចក្តីព្រៀងកិច្ចព្រមព្រៀង ស្តីពីទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែន និងការឆ្លងកាត់នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែន។

អគ្គនាយកដ្ឋានបានសម្របសម្រួល តាមដាន ពិនិត្យ និងដោះស្រាយលើការងារសំខាន់ៗដូចខាងក្រោម៖

- បានរៀបចំបែបបទដាក់ដំណើរការជាផ្លូវការនូវច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ណងអៀនស្របតាមស្មារតីនៃកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៨ ដើម្បីតភ្ជាប់ផ្លូវដឹកជញ្ជូនជំរុញកំណើនសេដ្ឋកិច្ចពាណិជ្ជកម្ម និងទេសចរណ៍រវាងប្រទេសទាំងពីរ(កម្ពុជា-ថៃ)

- បានពិនិត្យ និងរៀបចំបំពេញបែបបទដែលអនុញ្ញាតឱ្យរដ្ឋបាលខេត្តប៉ៃលិនចុះហត្ថលេខាជាមួយអាជ្ញាធរខេត្តចន្ទបុរីលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃស្តីពីការសាងសង់ស្ពានព្រំដែនថ្មីនៅច្រកទ្វារព្រំដែនអន្តរជាតិព្រំបានផាកាត

- បានស្នើទៅភាគីវៀតណាមតាមរយៈការទូតអំពីការបើកច្រកទ្វារអន្តរជាតិនៅកំពង់ផែទេសចរណ៍ខេត្តកំពតដើម្បីតភ្ជាប់ទៅកោះត្រល់(ភូគុក)នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

➢ **ការគ្រប់គ្រងប័ណ្ណព្រំដែន**

ចាប់តាំងពីដាក់ឱ្យដំណើរការប្រើប្រាស់ជាផ្លូវការនូវប័ណ្ណព្រំដែនកម្ពុជា-ថៃ និងប័ណ្ណព្រំដែនកម្ពុជា-ឡាវ រហូតមកដល់បច្ចុប្បន្ន ក្រសួងមហាផ្ទៃបានធ្វើការតាមដានត្រួតពិនិត្យ និងផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងសម្ភារជូនទៅរដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ និងប្រទេសឡាវជាប្រចាំ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ដំណើរការផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋឱ្យប្រព្រឹត្តទៅដោយរលូននិងប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនេះក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងបង្កើតការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃបានឆាប់រហ័ស ងាយស្រួលនិងកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យអនុវត្តសាកល្បងការផ្តល់សេវាប័ណ្ណ ព្រំដែនកម្ពុជា-ថៃនៅរដ្ឋបាលក្រុង ស្រុក នៃខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤។ ទន្ទឹមនេះ ក្នុងនាមក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានបានសម្របសម្រួលជាមួយភាគីថៃដើម្បីពង្រីកវិសាលភាពនៃការប្រើប្រាស់ប័ណ្ណព្រំដែនដោយអនុញ្ញាតឱ្យអ្នកកាន់ប័ណ្ណព្រំដែនថៃអាចធ្វើដំណើរចូលមកទឹកដីកម្ពុជារហូតដល់ខេត្តសៀមរាបក្នុងគោលដៅទេសចរណ៍។ ក្នុងការគាំទ្រនិងជំរុញដល់ការងារនេះ អគ្គនាយកដ្ឋានក៏បានអនុវត្តនូវកិច្ចការសំខាន់ៗមួយចំនួនដូចជាការផ្សព្វផ្សាយ និងណែនាំអនុវត្តនូវសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលខាងលើ ដល់រដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុកពាក់ព័ន្ធ បណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុកនៃខេត្តជាប់ព្រំដែនថៃ ការបំពាក់ឧបករណ៍បោះពុម្ព និងការបោះពុម្ព QR Code លើប័ណ្ណព្រំដែនកម្ពុជា-ថៃ។

ក្នុងឆ្នាំ២០២៤នេះ បានផ្តល់សេវាប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋប្រើប្រាស់សរុបចំនួន**២១៩.៤៧៥ក្បាល** ក្នុងនោះ៖

- រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ៖ បានចេញប័ណ្ណចំនួន**១៧៦.៤៦៨ក្បាល** ក្នុងនោះរួមមានខេត្តបន្ទាយមានជ័យចំនួន**១១៤.៣៤៧**ក្បាល ខេត្តបាត់ដំបងចំនួន **២៨.៨៣៦**ក្បាល ខេត្តឧត្តរមានជ័យចំនួន **៤២.៨១១**ក្បាល ខេត្តប៉ៃលិនចំនួន **២៨៣១១**ក្បាល និងខេត្តកោះកុងចំនួន **៤.៩៧៤**ក្បាល
- រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ៖ បានចេញប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋក្នុងខេត្តស្ទឹងត្រែងសរុបចំនួន **១៩៦**ក្បាល។

### ២.៣.៤.ការតាមដាន និងគាំទ្រការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

#### ២.៣.៤.១. សកម្មភាពនៃការចុះគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងវាយតម្លៃ

នៅក្នុងឆ្នាំ២០២៤នេះ អគ្គនាយកដ្ឋានបានចាត់មន្ត្រីជំនាញចុះតាមដានត្រួតពិនិត្យនិងវាយតម្លៃ ពិនិត្យនីត្យានុកូលភាព ការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំនួន ៨ នៃរាជធានីភ្នំពេញ ដោយផ្តោតលើការងារគ្រប់គ្រងរដ្ឋបាល របៀបរបបបំពេញការងារ និងការគ្រប់គ្រងបុគ្គលិក ការបំពេញតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រី ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ការពិនិត្យនីត្យានុកូលភាពលើដីកា លិខិតស្នាមរដ្ឋបាល ឬឯកសារនានា។

ទន្ទឹមនេះ អគ្គនាយកដ្ឋានបានធ្វើលិខិតក្នុងនាមក្រសួងមហាផ្ទៃដោយណែនាំដល់រដ្ឋបាលរាជធានី ខេត្តឱ្យរៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារបញ្ចប់អាណត្តិរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុកខណ្ឌអាណត្តិទី៣

(២០១៩-២០២៤)ដើម្បីឆ្លុះបញ្ចាំងនូវសមិទ្ធផលដែលក្រុមប្រឹក្សាខិតខំសម្រេចបាននៅក្នុងអាណត្តិការងារប្រាំឆ្នាំរបស់ខ្លួន។

អគ្គនាយកដ្ឋានបានរៀបចំកិច្ចប្រជុំពិនិត្យមើលវឌ្ឍនភាពការងាររបស់រដ្ឋបាលរាជធានី ខេត្តដែលសម្រេចបាន គិតចាប់តាំងពីដើមអាណត្តិរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា រហូតមកដល់ពេលបច្ចុប្បន្ន និងទស្សនវិស័យទៅមុខនៅក្នុងការគ្រប់គ្រងដឹកនាំរដ្ឋបាលរាជធានី ខេត្ត ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងឯកឧត្តមសន្តិបណ្ឌិត **ម៉ៅ ច័ន្ទតារា** រដ្ឋលេខាធិការប្រចាំការ តំណាងដ៏ខ្ពង់ខ្ពស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងនោះរួមមានចំនួន **១០រាជធានី ខេត្ត** គឺរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តព្រៃវែង ខេត្តព្រះសីហនុ ខេត្តតាកែវ ខេត្តស្ទឹងត្រែង ខេត្តសៀមរាប ខេត្តកណ្តាល និងខេត្តត្បូងឃ្មុំ។

ក្រសួងមហាផ្ទៃ បានពិនិត្យនីត្យានុកូលភាព លើដីកាស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្តអាណត្តិទី៤ និងកំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្តមួយចំនួន ព្រមទាំងបានតាមដាន និងពិនិត្យ មើលដំណើរការកិច្ចប្រជុំលើកទី១ និងកិច្ចប្រជុំលើកទី២ របស់ក្រុមប្រឹក្សារាជធានី ខេត្ត ស្របតាមការណែនាំរបស់ក្រសួងមហាផ្ទៃ។

### ២.៣.៤.២. ការគាំទ្រ ការពង្រឹងតួនាទីភារកិច្ចរបស់មេធាវីនៅរដ្ឋបាលរាជធានី ខេត្ត

ក្នុងឆ្នាំ២០២១ កន្លងមក ក្រសួងមហាផ្ទៃបានដាក់ចេញប្រកាសលេខ ២១៧៥ ប្រក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ស្តីពីក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត និងប្រកាសលេខ ៥០៣០ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការកែសម្រួលប្រការ២ នៃប្រកាសលេខ ២១៧៥ ប្រក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្តដើម្បីលើកកម្ពស់ការគោរព និងពង្រឹងគោលការណ៍នីត្យានុកូលភាពនៃលិខិតបទដ្ឋានគតិយុត្ត និងសេចក្តី-សម្រេចនានារបស់រដ្ឋបាលរាជធានី ខេត្ត និងធានាបានផលប្រយោជន៍ស្របច្បាប់របស់រដ្ឋបាលរាជធានី ខេត្តនៅពេលមានបណ្តឹងតវ៉ា ឬបណ្តឹងផ្សេងៗ។ បន្ទាប់ពីបានដាក់ចេញនូវប្រកាសខាងលើនាពេលបច្ចុប្បន្ននេះ រដ្ឋបាលរាជធានី ខេត្តមានសមាសភាពមេធាវីប្រចាំរដ្ឋបាលរាជធានីខេត្តនៅទូទាំងប្រទេសមានចំនួនសរុប**៧៨រូប**។ ក្នុងឆ្នាំ២០២៤ ក្រសួងមហាផ្ទៃ បានចេញប្រកាសទទួលស្គាល់ និងផ្លាស់ប្តូរមេធាវីប្រចាំខេត្តចំនួន **២រូប** សម្រាប់ខេត្តព្រៃវែង និងខេត្តរតនគិរី។

### ២.៣.៤.៣. ការគាំទ្រការរៀបចំសន្និបាតបូកសរុបលទ្ធផលការងាររបស់រដ្ឋបាលរាជធានី ខេត្ត

ផ្អែកតាមស្មារតីនៃសេចក្តីណែនាំ០៣៤ របស់ក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ដើម្បីឆ្លុះបញ្ចាំងអំពីសមិទ្ធផលការងារបញ្ហាប្រឈម និងកាលានុវត្តភាព ព្រមទាំងដាក់ចេញនូវទិសដៅការងារសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។

នាដើមឆ្នាំ២០២៤ បានសហការសម្របសម្រួល និងគាំទ្រដល់រដ្ឋបាលរាជធានី ខេត្តទាំង២៥ ក្នុងការរៀបចំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ ក្រោមអធិបតីភាពប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ដោយមានការចូលរួមពីគ្រប់មន្ទីរ អង្គភាពជុំវិញខេត្ត។

ដោយឡែកក្នុងឆ្នាំ២០២៥នេះ ក្រសួងមហាផ្ទៃបានសម្របសម្រួល និងណែនាំដល់រដ្ឋបាលរាជធានី ខេត្តឱ្យចាត់ចែងរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ ស្របទៅតាមគោលការណ៍ណែនាំជាធរមានឱ្យបានរួចរាល់យ៉ាងយូរដំណាច់ខែមករា ឆ្នាំ២០២៥។

## ២.៤. ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស

### ២.៤.១.ការធ្វើវិភាគមុខងារ រចនាសម្ព័ន្ធស្ថាប័ន របៀបរបបធ្វើការងារ និងទំនើបកម្មស្ថាប័ន

#### ២.៤.១.១. ការវិភាគមុខងារ និងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានរដ្ឋបាល

ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណគឺការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើបប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាជនកាន់តែល្អប្រសើរ។ ផ្តើមចេញពីស្នូលនៃយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវសេចក្តីណែនាំលេខ ០១ សណន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងសារាចរលេខ០៨ សរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ដើម្បីឱ្យគ្រប់ក្រសួង ស្ថាប័នទាំងអស់យកទៅអនុវត្ត ដោយក្នុងនោះត្រូវគិតគូពិចារណាទៅលើ៖ ១). ការពង្រឹង និងការកែទម្រង់ស្ថាប័ន ២). ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ និង៣). ការលើកកម្ពស់ និងពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ។

អនុវត្តតាមស្មារតីនៃសេចក្តីណែនាំ និងសារាចររបស់រាជរដ្ឋាភិបាលខាងលើ និងផ្អែកតាមអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានរដ្ឋបាលបានធ្វើការពិនិត្យឡើងវិញ វិភាគមុខងារ និងរចនាសម្ព័ន្ធ ព្រមទាំងធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញការងារនៅក្នុងអគ្គនាយកដ្ឋានរដ្ឋបាល ដូចខាងក្រោម៖

- អគ្គនាយកដ្ឋានរដ្ឋបាលមានមុខងារស្នូលចំនួន៣ រួមមាន៖
    - មុខងារគ្រប់គ្រងរដ្ឋបាលដែនដី
    - មុខងារគាំទ្រ និងអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
    - មុខងារគ្រប់គ្រងសមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សហគមន៍ជនជាតិដើមភាគតិច និងគណបក្សនយោបាយ
- អគ្គនាយកដ្ឋានរដ្ឋបាលមានមុខងាររង(មុខងារគាំទ្រនិងមុខងារជំនាញ/ឯកទេស)៖
    - ជានា និងសម្របសម្រួលលើការអនុវត្តគោលនយោបាយ កម្មវិធីជាតិ ផែនការយុទ្ធសាស្ត្រ ច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
    - សិក្សា និងលើកយោបល់ក្នុងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
    - រៀបចំប្រព័ន្ធគាំទ្រ និងសម្របសម្រួលទៅលើការបំពេញតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
    - គាំទ្រ និងសហការសម្របសម្រួលលើការងាររដ្ឋបាល ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
    - គ្រប់គ្រងសកម្មភាពការងាររបស់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែន ច្រកទ្វារកំពង់ផែសមុទ្រ និងសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងគ្រប់គ្រងការផ្តល់ប័ណ្ណព្រំដែនជូនដល់ប្រជាពលរដ្ឋ
    - សិក្សា ពិនិត្យ និងលើកយោបល់ពាក់ព័ន្ធនឹងការបង្កើត ការបំបែក ការលុបចោល ការកែសម្រួលព្រំប្រទល់រដ្ឋបាលនិង ការកំណត់ឈ្មោះ ឬការកែសម្រួលឈ្មោះរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការបង្កើត ការបំបែក ឬការលុបចោលភូមិ

- ត្រួតពិនិត្យនីត្យានុកូលភាពទៅលើដីកា និងសេចក្ដីសម្រេចនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ជានា និងសម្របសម្រួលលើការអនុវត្តច្បាប់ស្ដីពីគណបក្សនយោបាយ និងច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- ផ្ដល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព នៃការផ្ដល់សេវារដ្ឋបាល សេវាសាធារណៈ និងការសម្រុះសម្រួលដោះស្រាយបណ្ដឹងនៅថ្នាក់មូលដ្ឋានក្រោមជាតិគាំទ្រដល់កិច្ចដំណើរការរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការកសាង និងអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន គោលការណ៍អភិបាលកិច្ចល្អ គណនេយ្យភាពសង្គម សុចរិតភាព និងភាពជាអ្នកដឹកនាំនៅថ្នាក់ក្រោមជាតិ
- សហការពិនិត្យ និងលើកយោបល់ពាក់ព័ន្ធនឹងការគ្រប់គ្រង និងការចាត់ចែងមន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន
- សហការរៀបចំ និងដាក់ឱ្យអនុវត្ត ព្រមទាំងតាមដាន និងត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្ថាប័ន ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សហការរៀបចំប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្ស និងផែនការបណ្ដុះបណ្ដាល អប់រំ កសាងសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំបែបបទផ្លាស់ប្ដូរ និងទទួលស្គាល់សមាជិកក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់កំណត់
- រៀបចំ និងគ្រប់គ្រងសំណុំឯកសារ និងទិន្នន័យសមាជិកក្រុមប្រឹក្សា និងបុគ្គលិក នៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្ដល់ការគាំទ្រដល់បណ្ដាខេត្តជាប់ព្រំដែនក្នុងការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍតំបន់ព្រំដែនប្រកបដោយចីរភាព
- កៀរគរ និងសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការរៀបចំ គ្រប់គ្រង និងអនុវត្តគម្រោង ឬកម្មវិធីនានាដែលទាក់ទងនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សហការគាំទ្រ និងសម្របសម្រួលដល់ដំណើរការការងារបោះឆ្នោត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- គ្រប់គ្រងឯកសារ ការងារបុគ្គលិក ភស្ដុភារ និងគណនេយ្យរបស់អគ្គនាយកដ្ឋានរដ្ឋបាល
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់អគ្គនាយកដ្ឋានរដ្ឋបាល តាមការកំណត់ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់ជូន។

### ២.៤.១.២. ការពង្រឹងរបៀបរបបការងារ

ផ្អែកតាមស្មារតីនៃអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា អគ្គនាយកដ្ឋានរដ្ឋបាលបានណែនាំដល់គ្រប់នាយកដ្ឋានចំណុះទាំងអស់ខិតខំប្រឹងប្រែងពង្រឹងការគ្រប់គ្រងវត្តមានមន្ត្រីក្រោមឱវាទរបស់ខ្លួន និងរៀបចំសម្រង់ព័ត៌មានស្ដីពីប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ដោយធ្វើការបិទតាមក្ដារខៀនព័ត៌មានរបស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។

### ២.៤.២.ការពង្រឹងការគ្រប់គ្រងធនធានមនុស្ស

#### ២.៤.២.១. ការរៀបចំផែនការបុគ្គលិក

ផ្អែកលើមូលដ្ឋាននៃការវិភាគមុខងារ និងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា ព្រមទាំងស្របតាមការសិក្សាទៅលើតម្រូវការធនធានមនុស្សនៅក្នុងឆ្នាំ២០២៥ ខាងមុខនេះ សំដៅធានាបាននូវនិរន្តរភាពការងាររបស់អគ្គនាយកដ្ឋានរដ្ឋបាលឱ្យមានដំណើរការល្អប្រសើរប្រកបដោយប្រសិទ្ធភាព ឆ្លើយតបទៅនឹងទំហំវិសាលភាពការងារបានឆាប់រហ័ស និងទាន់ពេលវេលា ស្របតាមបេសកកម្មរបស់អគ្គនាយកដ្ឋានរដ្ឋបាល និងក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានរដ្ឋបាលបានសិក្សា និងរៀបចំ ផែនការបុគ្គលិកសម្រាប់ឆ្នាំ២០២៥ ដោយធ្វើការបង្វែរពីការស្នើសុំជ្រើសរើសមន្ត្រីក្របខ័ណ្ឌ ទៅជាមន្ត្រីជាប់កិច្ចសន្យា សំដៅធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការចំណាយថវិកាជាតិ។ ពាក់ព័ន្ធនឹងផែនការបុគ្គលិកនេះ អគ្គនាយកដ្ឋានរដ្ឋបាលបានធ្វើការបែងចែកទៅតាមនាយកដ្ឋានចំណុះនីមួយៗស្របនឹងជំនាញតម្រូវការជាអាទិភាពដូចខាងក្រោម៖

| | |
|---|---|
| - ជំនាញរដ្ឋបាលសាធារណៈ | ចំនួន ៨រូប |
| - ជំនាញព័ត៌មានវិទ្យា | ចំនួន ៧រូប |
| - ជំនាញខេមរភាសា | ចំនួន ១រូប |
| - ជំនាញហិរញ្ញវត្ថុ | ចំនួន ៣រូប |
| - ជំនាញវិស្វកម្មសំណង់ស៊ីវិល | ចំនួន ៣រូប |
| - ជំនាញគោលនយោបាយសាធារណៈ | ចំនួន១រូប |
| - ជំនាញផែនការ | ចំនួន ១រូប |
| - ជំនាញភាសាថៃ | ចំនួន ១រូប |
| - ជំនាញភាសាវៀតណាម | ចំនួន១រូប។ |

#### ២.៤.២.២. ការជ្រើសរើសបុគ្គលិក (បុគ្គលិកកិច្ចសន្យា)

នៅក្នុងឆ្នាំ២០២៤កន្លងមក អគ្គនាយកដ្ឋានរដ្ឋបាលបានជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាដើម្បីជួយបំពេញមុខងារជាជំនួយការអង្គភាព ដែលបានបំពេញការងារចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ ផ្អែកតាមអនុក្រឹត្យលេខ ២៦អនក្រ.បក ស្តីពីការជ្រើសរើស និងប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា ក្រសួង ស្ថាប័ន ត្រូវរៀបចំសេចក្តីព្រាងផែនការរួមឱ្យបានជាក់លាក់ស្តីពីតម្រូវការ នៃការប្រើប្រាស់ចំនួនមន្ត្រីជាប់កិច្ចសន្យាជារៀងរាល់ឆ្នាំ សម្រាប់ឆ្នាំបន្ទាប់ដោយផ្អែកលើតម្រូវការជាក់ស្តែងឱ្យបានមុនដំណាច់ត្រីមាសទី១ នៃឆ្នាំនីមួយៗ ។ ហេតុនេះ អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំបែបបទ និងនីតិវិធីនៃការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា ដើម្បីស្នើសុំប្រើប្រាស់បន្តសម្រាប់មន្ត្រីជាប់កិច្ចសន្យាចំនួន **៣២រូប** ក្នុងឆ្នាំ២០២៥ នៃនាយកដ្ឋាននីមួយៗ ចំណុះអគ្គនាយកដ្ឋានរដ្ឋបាល។

#### ២.៤.២.៣. ការរៀបចំប្រព័ន្ធលើកទឹកចិត្ត និងការផ្តល់គ្រឿងឥស្សរិយយស មេដាយស្ថាបនាជាតិ

ដើម្បីជាការលើកទឹកចិត្ត និងចារឹកទុកនូវស្នាដៃគុណបំណាច់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការស៊ីវិល ដែលបានខិតខំប្រឹងប្រែងបំពេញការងារដោយយកចិត្តទុកដាក់ មានស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបានសមិទ្ធផលនានាជាច្រើនក្នុងការចូលរួមចំណែកអនុវត្តនូវបេសកកម្មរបស់អគ្គនាយកដ្ឋានរដ្ឋបាលក៏ដូចជាក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំប្រព័ន្ធលើកទឹកចិត្តមន្ត្រីរបស់ខ្លួនតាមរូបភាពមួយចំនួន ដូចខាងក្រោម៖

- ការស្នើសុំផ្តល់គ្រឿងឥស្សរិយយស និងមេដាយការងារ(ចំនួន ១០៥រូប)

- ការស្នើសុំផ្តល់បណ្ណសរសើរ(ចំនួន ១៧៣ រូប)
- ការស្នើសុំដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមវេនជ្រើសរើស(ចំនួន ១៩២រូប)

២.៤.២.៤. ការពង្រឹងការដឹកនាំ ការគ្រប់គ្រងមន្ត្រី

### ២.៤.៣. ការពង្រឹងការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

២.៤.៣.១. ការងារកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ក្នុងឆ្នាំ២០២៤នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានកសាងលិខិតបទដ្ឋានគតិយុត្ត និងសម្រេចបានរួមមាន អនុក្រឹត្យចំនួន ២ ប្រកាសចំនួន ៤៩ សេចក្តីសម្រេចចំនួន ៣ និងសេចក្តីណែនាំចំនួន ១។ ព្រមជាមួយគ្នានេះ អគ្គនាយកដ្ឋានរដ្ឋបាលបាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុង ដែលរួមមានសេចក្តីព្រាងវិសោធនកម្មច្បាប់ចំនួន ១ សេចក្តីព្រាងអនុក្រឹត្យចំនួន ៤ សេចក្តីព្រាងប្រកាសចំនួន ១ សេចក្តីព្រាងសេចក្តីសម្រេចចំនួន ១ សេចក្តីព្រាងសេចក្តីណែនាំចំនួន ៦ និងសេចក្តីព្រាងផ្សេងៗចំនួន ១។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលបានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការកសាងលិខិតបទដ្ឋានគតិយុត្តិ និងសម្រេចបានរួមមានៈច្បាប់ស្តីពីប្រព័ន្ធទឹកកខ្វក់ចំនួន ១ និងប្រកាសចំនួន ១ ។ បច្ចុប្បន្ននេះ អគ្គនាយកដ្ឋាន បាននិងកំពុងសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត រួមមានសេចក្តីព្រាងច្បាប់ចំនួន ១ សេចក្តីព្រាងព្រះរាជក្រឹត្យចំនួន ១ សេចក្តីព្រាងអនុក្រឹត្យចំនួន ១ សេចក្តីព្រាងប្រកាសចំនួន ៦ សេចក្តីព្រាងកិច្ចព្រមព្រៀងចំនួន ១ សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងចំនួន ៤ និងសេចក្តីព្រាងកម្មវិធីជាតិចំនួន ១។

## ២.៥. ការលើកកម្ពស់ការផ្តល់សេវាសាធារណៈក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ

### ២.៥.១. ការផ្តល់សេវារដ្ឋបាលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ

២.៥.១.១. ការផ្តល់សេវាចុះបញ្ជីគណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិច

ក. <u>ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល</u>

បច្ចុប្បន្ន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃមានចំនួនសរុប ៦.៤១៨ (សមាគមចំនួន ២.៨៦០ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣.៥៥៨) ក្នុងនោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលសម្រាប់នីតិបុគ្គលមានចំនួនសរុប ៧៦(សមាគមចំនួន ៧១ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៥) និងសមាគមសម្រាប់ជនបរទេសចំនួន៨ ព្រមទាំងសហគមន៍ជនជាតិដើមភាគតិចមានចំនួន ១៥៤ ។ ដោយឡែកបន្ទាប់ពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន (ខែសីហា ឆ្នាំ២០១៥) រហូតមកដល់ដំណាច់ឆ្នាំ២០២៤នេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ មានចំនួនសរុប ២.០១២ ក្នុងនោះ សមាគមមានចំនួន ១.១៦៨ និងអង្គការមិនមែនរដ្ឋាភិបាលមានចំនួន ៨៤៤។

នៅក្នុងឆ្នាំ២០២៤ អគ្គនាយកដ្ឋាន បានសម្រេចចុះឈ្មោះក្នុងបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ២៣១ (សមាគមចំនួន ១៥៤ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៧៧) ព្រមទាំងបានលុបឈ្មោះចេញពីបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៨៥ (សមាគមចំនួន ៣៩ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៤៦) និងសម្រេចចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចចំនួន ១ ផងដែរ។ បន្ថែមលើនេះ អគ្គនាយកដ្ឋានបានពិនិត្យ និងសម្រេចទទួលស្គាល់ស្ថានភាពនៃការប្រែប្រួលរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ២៤២ (សមាគម

ចំនួន ១១៧ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១២៥)។ អនុលោមតាមមាត្រា១០ និងមាត្រា២៥ នៃច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ក្នុងឆ្នាំ២០២៤ អគ្គនាយកដ្ឋានរដ្ឋបាលបានទទួលរបាយការណ៍បូកសរុបសកម្មភាពការងារ និងហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣របស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ៧៤២ (សមាគមចំនួន ១៧៦ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៥៦៦) ព្រមទាំងព័ត៌មានគណនីសរុបចំនួន ១៧១ (សមាគមចំនួន ៧៨ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៩៣)។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានក៏បានរៀបចំលិខិតជូនទៅក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីសុំផ្តល់បណ្ណសម្គាល់ ប្តូរប័ណ្ណសម្គាល់ និងផ្លាកលេខសម្គាល់យានជំនិះសរុបចំនួន ១៧២គ្រឿង (ទោចក្រយានយន្តចំនួន ១១៨គ្រឿង រថយន្តចំនួន ៥១គ្រឿង និងត្រីចក្រយានយន្តចំនួន ៣គ្រឿង) របស់សមាគមចំនួន ១១ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៥៦។

បន្ថែមលើនេះ អគ្គនាយកដ្ឋានបានរៀបចំធ្វើជំរឿនសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឆ្នាំ២០២៤ ក្នុងគោលបំណងដើម្បីកំណត់ចំនួនពិតប្រាកដរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះឈ្មោះក្នុងបញ្ជីនៅក្រសួងមហាផ្ទៃដែលនៅមានប្រតិបត្តិការ ក៏ដូចជាពង្រឹងការអនុវត្តច្បាប់ និងការបំពេញកាតព្វកិច្ចតាមការកំណត់ដោយច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ផ្អែកតាមលទ្ធផលនៃការធ្វើជំរឿនសមាគម និងអង្គការមិនមែនរដ្ឋាភិបាលរហូតមកដល់ពេលនេះ អគ្គនាយកដ្ឋានបានដាក់ចេញលិខិតជូនដំណឹងជាបន្តបន្ទាប់ជូនទៅសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលរហូតមកដល់ពេលនេះបានចំនួន ១.៣៦០ ក្នុងនោះសមាគមចំនួន ៥៥៧ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៨០៣ ដើម្បីឱ្យមកបំពេញកាតព្វកិច្ចតាមលក្ខខណ្ឌកំណត់ដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ទន្ទឹមនេះ ក៏បានរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល លើកទី៦ ក្រោមប្រធានបទ "**សិទ្ធិសេរីភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងបរិបទនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា**" ដោយមានការចូលរួមមកពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធតំណាងរដ្ឋបាលរាជធានី ខេត្ត តំណាងស្ថានទូតដៃ គូអភិវឌ្ឍន៍មួយចំនួន ព្រមទាំងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានសមាសភាពចូលរួមចំនួនប្រមាណ ៥២០(ប្រាំរយម្ភៃ)នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**។ នៅក្នុងឆ្នាំ២០២៤នេះ រាជរដ្ឋាភិបាលក៏បានសម្រេចឱ្យរៀបចំបង្កើតឡើងវិញនូវក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលដោះស្រាយសំណើនិងសំណូមពររបស់អង្គការសង្គមស៊ីវិល ដែលមានតំណាងមកពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលសរុបចំនួន១២។

### ខ. ការងារកិច្ចការគណបក្សនយោបាយ

បច្ចុប្បន្ននេះ គណបក្សនយោបាយបង្កើត និងចុះបញ្ជីនៅក្រសួងមហាផ្ទៃសរុបមានចំនួន **៥១ គណបក្ស** ក្នុងនោះគណបក្សនយោបាយចុះបញ្ជីមានចំនួន **៤៧** និងគណបក្សនយោបាយបង្កើតថ្មីមានចំនួន ៤។ ដោយឡែកនៅក្នុងឆ្នាំ២០២៤នេះ អគ្គនាយកដ្ឋានបានយកចិត្តទុកដាក់ក្នុងការបំពេញភារកិច្ចពាក់ព័ន្ធនឹងគណបក្សនយោបាយដោយបានលើកយោបល់ជូនថ្នាក់ដឹកនាំដើម្បីសម្រេចចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយចំនួន ៣ គឺ**គណបក្សជំនាន់ថ្មី គណបក្សបៃតង និងគណបក្សដើម្បីកម្ពុជា** និងសម្រេចអនុញ្ញាតឱ្យបង្កើតគណបក្សចំនួន៤ គឺ**គណបក្សបញ្ញាវន្តខ្មែរ គណបក្សសន្តិភាពជាតិ គណបក្សដំណើរឆ្ពោះទៅមុខ និងគណបក្សវីរភាពខ្មែរ** ព្រមទាំងសម្រេចលុបឈ្មោះ**គណបក្សបញ្ញាទំនើប** ចេញពីបញ្ជីគណបក្ស និងបដិសេធការស្នើសុំបង្កើតគណបក្សចំនួន ៨ គឺ**គណបក្សបៃតង គណបក្សអនាគតខ្មែរ គណបក្សខ្មែរស្រឡាញ់ខ្មែរ គណបក្សគ្រួសារខ្មែរ គណបក្សខ្មែរសន្តិភាព គណបក្សពលរដ្ឋសកម្ម គណបក្សយេនឌ័រកម្ពុជា និងគណបក្សវីរជនកម្ពុជា**។ បន្ថែមលើនេះ អគ្គនាយកដ្ឋាន បានពិនិត្យនិងសម្រេចទទួល

ស្គាល់ស្ថានភាពនៃការប្រែប្រួលរបស់គណបក្សនយោបាយចំនួន២៣ករណី និងបានទទួលរបាយការណ៍បូកសរុបសកម្មភាព សំខាន់ៗប្រចាំឆ្នាំ២០២៣ របស់គណបក្សនយោបាយ ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃចំនួន ៤២។

បន្ថែមលើពីនេះ អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំដាក់ចេញនូវសេចក្តីជូនដំណឹងណែនាំដល់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឱ្យបង្កលក្ខណៈងាយស្រួលដល់គ្រប់គណបក្សនយោបាយ ដែលបានចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា អាណត្តិទី៥ និងការបោះ-ឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣។

**២.៥.១.២. ការងារអន្តរាគមន៍ ដោះស្រាយបណ្តឹងតវ៉ា និងការងារដោះស្រាយសំណើ សំណូមពររបស់មហាជនក្នុងគេហទំព័រហ្វេសប៊ុក**

ក. <u>ការងារអន្តរាគមន៍ និងដោះស្រាយបណ្តឹងតវ៉ា</u>

ក្រសួងមហាផ្ទៃបានទទួលសំណើជាលាយលក្ខណ៍អក្សរពីប្រជាពលរដ្ឋស្នើសុំជួយអន្តរាគមន៍ដោះស្រាយទំនាស់ដីធ្លី ស្នើសុំចុះវាស់វែង កាត់ឆ្វៀលដី ដើម្បីចុះបញ្ជីចេញបណ្ណកម្មសិទ្ធិ ផ្លាស់ប្តូរបណ្ណកម្មសិទ្ធិ និងប្តឹងអាជ្ញាធរមូលដ្ឋានចំនួន **៧៤ករណី** ដែលសំណើទាំងនេះក្រសួងមហាផ្ទៃបានបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្តដើម្បីពិនិត្យ និងដោះស្រាយ។ រដ្ឋបាលរាជធានី ខេត្តបានពិនិត្យ និងដោះស្រាយសរុបចំនួន **២៤ករណី** ដោយបានឆ្លើយតបទៅសាមីសំណើ និងធ្វើរបាយការណ៍មកក្រសួងមហាផ្ទៃ អំពីលទ្ធផលសម្រេចបាននៃការដោះស្រាយទាំងនោះ និងនៅសល់ចំនួន **៥០ករណី**។

ខ. <u>ការងារដោះស្រាយសំណើ សំណូមពររបស់មហាជនក្នុងគេហទំព័រហ្វេសប៊ុក</u>

អគ្គនាយកដ្ឋានរដ្ឋបាលបានទទួលសំណើ សំណូមពររបស់មហាជនពី**ក្រុមការងារហ្វេសប៊ុកឯកឧត្តមអភិសន្តិបណ្ឌិត ហ្វេសប៊ុកសម្តេចក្រឡាហោម** និង**ហ្វេសប៊ុកក្រសួងមហាផ្ទៃ** និងបានបញ្ជូនឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងដោះស្រាយចំនួន **១១០ករណី**។ បច្ចុប្បន្ននេះ រដ្ឋបាលរាជធានី ខេត្តបានធ្វើការពិនិត្យ ដោះស្រាយ និងឆ្លើយតបទៅសាមីសំណើវិញ បានចំនួន **៦២ករណី** និងនៅសល់ចំនួន **៤៨ករណី**។

## ២.៦. ការងារបច្ចេកវិទ្យាឌីជីថល

### ២.៦.១. ការលើកកម្ពស់ការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យាឌីជីថលបម្រើដល់ការគ្រប់គ្រងរដ្ឋបាលទូទៅ

២.៦.១.១. ការរៀបចំថ្នាលឌីជីថលសម្រាប់គ្រប់គ្រង និងផ្តល់សេវារដ្ឋបាល

អគ្គនាយកដ្ឋានក៏បានរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមានដូចខាងក្រោម៖

- បានធ្វើបច្ចុប្បន្នភាពទៅលើប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) ប្រព័ន្ធគ្រប់គ្រងគម្រោងថ្នាក់ក្រោមជាតិ (PID) និងប្រព័ន្ធតាមដានការអនុវត្តផែនការថវិកាប្រចាំឆ្នាំ (NAD)
- កំពុងដំណើរការអនុវត្តនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេស
- បាននិងកំពុងដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធផ្តល់សេវារដ្ឋបាលតាមអនឡាញនៅថ្នាក់រាជធានី ខេត្តចំនួន ១២ លើប្រភេទសេវារដ្ឋបាលចំនួន ១១៧ ក្នុងវិស័យចំនួន ៤ រួមមានវិស័យទេសចរណ៍ វិស័យវប្បធម៌ និងវិចិត្រសិល្បៈ វិស័យឧស្សាហកម្ម និងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីរបាយការណ៍សិក្សាគំរូស្តង់ដា និងការពង្រីកវិសាលភាព រង្វាភិបាលអេឡិចត្រូនិកសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានការអញ្ជើញចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តចំនួន ៤ ក្រុង ស្រុកចំនួន ៨

- បានរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវការស្នើសុំសេវាចុះបញ្ជីអង្គការ សមាគម និងគណបក្ស នយោបាយតាមប្រព័ន្ធឌីជីថល

- បានរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវការស្នើសុំសេវារដ្ឋបាលនៅតាមអង្គភាពច្រកចេញចូលតែមួយរបស់រដ្ឋបាលរាជធានី ខេត្ត និងដាក់ឱ្យទូទាត់ថ្លៃសេវារដ្ឋបាលតាមប្រព័ន្ធ (Payment Hub)។

### ២.៦.១.២.ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

- បាននិងកំពុងរៀបចំជ្រើសរើសទីប្រឹក្សាព័ត៌មានវិទ្យារយៈពេលខ្លីតាមរយៈគម្រោងគណនេយ្យភាពសង្គម ដើម្បីធ្វើបច្ចុប្បន្នភាពមុខងារកម្មវិធីទូរសព្ទដៃគណនេយ្យភាពសង្គម លើប្រព័ន្ធប្រតិបត្តិការ IOS និង Android ដើម្បីឱ្យសាធារណជនកាន់តែងាយស្រួលប្រើប្រាស់ និងទទួលបានព័ត៌មានត្រលប់ពីប្រជាពលរដ្ឋទៅលើការផ្តល់សេវារបស់អង្គភាពផ្តល់សេវា

-រដ្ឋបាលថ្នាក់ក្រោមជាតិ បាននិងកំពុងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា ដើម្បីលើកកម្ពស់និងផ្តល់ភាពងាយស្រួលក្នុងការទំនាក់ទំនងការងារ ការផ្សព្វផ្សាយព័ត៌មាន ការផ្តល់យោបល់ត្រឡប់ ការផ្តល់សេវារដ្ឋបាល និងការអនុវត្តភារកិច្ចរបស់ខ្លួនតាមរយៈប្រព័ន្ធ Facebook, Telegram, Website ជាដើម។ ព័ត៌មានសំខាន់ៗ ដែលបានផ្សព្វផ្សាយជូនប្រជាពលរដ្ឋ រួមមានព័ត៌មានស្តីពីការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាព/ការិយាល័យច្រកចេញចូលតែមួយ ការងារគណនេយ្យភាពសង្គម កិច្ចលទ្ធកម្មសាធារណៈ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ល។

### ២.៦.១.៣.ការរៀបចំប្រព័ន្ធគ្រប់គ្រងការងារតាមឌីជីថល

ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រង និងតាមដានរាល់ឯកសារចេញ-ចូលផ្ទៃក្នុង សំដៅលើកកម្ពស់ប្រសិទ្ធភាពការងារឱ្យបានកាន់តែល្អប្រសើរ និងឆ្លើយតបទាន់ពេលវេលា អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងលំហូរឯកសាររួមមួយ ដោយបានដាក់ឱ្យអនុវត្តសាកល្បងក្នុងដំណាក់កាលទី១ និងទី២ ខែកញ្ញា ឆ្នាំ២០២៤ ជាមួយនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត។ ជាជំហានបន្ទាប់ នៅដើមឆ្នាំ២០២៥ខាងមុខនេះ អគ្គនាយកដ្ឋាននឹងដាក់ឱ្យអនុវត្តជាផ្លូវការនូវការគ្រប់គ្រង និងតាមដានរាល់លំហូរឯកសារនៅគ្រប់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាល។ ជាមួយនឹងរៀបចំនិងកសាងប្រព័ន្ធគ្រប់គ្រងលំហូរឯកសារផ្ទៃក្នុងនេះ អគ្គនាយកដ្ឋានក៏បានសហការជាមួយអគ្គនាយកដ្ឋានឌីជីថល និងបច្ចេកវិទ្យាក្រសួងមហាផ្ទៃ ក្នុងការសិក្សា និងអនុវត្តនូវប្រព័ន្ធគ្រប់គ្រងឯកសារតាមប្រព័ន្ធ DMS ផងដែរ។

### ២.៦.១.៤.ការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមអង្គភាពនានា

នាពេលបច្ចុប្បន្ននេះ អគ្គនាយកដ្ឋានរដ្ឋបាលបានបង្កើត និងកំពុងប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងទិន្នន័យដូចខាងក្រោម៖

- ប្រព័ន្ធទិន្នន័យគ្រប់គ្រងប័ណ្ណព្រំដែនត្រូវបានបង្កើត និងដាក់ឱ្យរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃប្រើប្រាស់សម្រាប់ផលិតប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តជាប់ព្រំដែន កម្ពុជា-ថៃ

- ប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបាន និងកំពុងអភិវឌ្ឍន៍ក្នុងគោលបំណងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបញ្ចូលទិន្នន័យអំពីវឌ្ឍនភាព និងលទ្ធផលនៃការអនុវត្ត

- គម្រោងតាមជំហាន និងវដ្តនៃការអនុវត្តគម្រោង

- ដើម្បីឆ្លើយតបទៅសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិលនៅក្នុងវេទិកានាពេលកន្លងមក ក៏ដូចជាដើម្បីជំរុញបរិវត្តកម្មឌីជីថលនៅក្នុងប្រទេសកម្ពុជា អគ្គនាយកដ្ឋានរដ្ឋបាល បាននិងកំពុងសហការជាមួយអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំ បន្តអភិវឌ្ឍន៍ប្រព័ន្ធចុះបញ្ជីនិងគ្រប់គ្រងទិន្នន័យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលតាមប្រព័ន្ធឌីជីថល ដោយគ្រោងដាក់ឱ្យដំណើរការសាកល្បងក្នុងជំហានទី១ ក្នុងឆ្នាំ២០២៥ខាងមុខនេះ សំដៅបង្កលក្ខណៈងាយស្រួលជូនដល់ប្រជាពលរដ្ឋក្នុងការចុះបញ្ជីនិងការធ្វើបច្ចុប្បន្នភាពទិន្នន័យសំខាន់ៗឱ្យកាន់តែឆាប់រហ័ស តម្លាភាព គណនេយ្យភាព និងបរិយាបន្ន ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។

ទន្ទឹមនេះ អគ្គនាយកដ្ឋាន បាននិងកំពុងរៀបចំកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យបុគ្គលិក និងមន្ត្រីរាជការស៊ីវិលនៅអគ្គនាយកដ្ឋានរដ្ឋបាល និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រព័ន្ធនេះ នឹងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីដែលទទួលបន្ទុកអនុវត្តលើកិច្ចការនេះ ឱ្យបំពេញការងាររបស់ខ្លួនបានឆាប់រហ័ស ឆ្លើយតបទៅនឹងតម្រូវការការងារជាក់ស្តែងរបស់ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងការពង្រឹងការអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យខាងលើ អគ្គនាយកដ្ឋានបានអនុវត្ត នូវកិច្ចការមួយចំនួនដោយសម្រេចបាននូវលទ្ធផលជាបន្តបន្ទាប់ដូចខាងក្រោម៖

➢ **ការងារអភិវឌ្ឍន៍សមត្ថភាពផ្នែកបច្ចេកវិទ្យាឌីជីថល៖**

អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តនូវកិច្ចការសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

- បានបណ្តុះបណ្តាលដល់រដ្ឋបាលក្រុងស្រុកនៃខេត្តជាប់ព្រំដែនថៃនៅក្នុងការផ្តល់សេវាប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋ ព្រមទាំងបំពាក់ឧបករណ៍ផលិតប័ណ្ណព្រំដែន និងបង្រៀនអំពីវិធីប្រើប្រាស់

- បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអង្គភាពច្រកចេញចូលតែមួយរបស់រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ និងរដ្ឋបាលក្រុង ស្រុកចំណុះខេត្តទាំងនេះអំពីការបោះពុម្ព QR Code លើប័ណ្ណព្រំដែនកម្ពុជា-ថៃ

- បានសម្របសម្រួលកិច្ចការមួយចំនួន ដើម្បីដាក់ឱ្យដំណើរការនូវការប្រើប្រាស់ប្រព័ន្ធ QR Code សម្រាប់ប្រជាពលរដ្ឋដែលប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ធ្វើដំណើរចេញចូលឆ្លងកាត់ព្រំដែន នៅខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង។

➢ **ការងារសហប្រតិបត្តិការផ្នែកបច្ចេកវិទ្យាឌីជីថល៖**

ក្នុងការកែសម្រួលការអភិវឌ្ឍ និងការដំឡើងប្រព័ន្ធប្រតិបត្តិបច្ចេកទេសនៃប្រព័ន្ធទិន្នន័យក្រុមការងារអគ្គនាយកដ្ឋានបានធ្វើកិច្ចសហការជាមួយភាគីពាក់ព័ន្ធដូចខាងក្រោម៖

- បានជួបប្រជុំពិភាក្សាជាមួយតំណាងអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ដើម្បីពិភាក្សាអំពីតម្រូវការឧបករណ៍នានា និងតម្រូវការផ្សេងៗដើម្បីរៀបចំដំឡើងម៉ាស៊ីនមេ សម្រាប់ប្រព័ន្ធទិន្នន័យគម្រោងក្នុងមជ្ឈមណ្ឌលទិន្នន័យ (Data Center) របស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ

- បានសហការជាមួយក្រុមការងារអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំដើម្បីដំឡើងនូវឧបករណ៍ប្រព័ន្ធប្រតិបត្តិ (Licensesd-VMWare)

- បានធ្វើសន្ទានកម្មប្រព័ន្ធគ្រប់គ្រងប័ណ្ណព្រំដែនរបស់អគ្គនាយកដ្ឋានរដ្ឋបាលជាមួយប្រព័ន្ធគ្រប់គ្រងច្រកទ្វារព្រំដែនរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងបោះពុម្ព QR Code នៅលើប័ណ្ណព្រំដែនកម្ពុជា-ថៃ។

**៣. បញ្ហាប្រឈម**

ក្នុងការអនុវត្តការងារប្រចាំថ្ងៃ ដែលជាតួនាទីភារកិច្ចរបស់អគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីឆ្លើយតបនឹងការអនុវត្តផែនការសកម្មភាពផែនការយុទ្ធសាស្ត្រ និងគោលនយោបាយនានារបស់ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានបានពិនិត្យឃើញអំពីបញ្ហាប្រឈមសំខាន់ៗមួយចំនួនៈ

- អគ្គនាយកដ្ឋានរដ្ឋបាលពុំទាន់មានទីប្រឹក្សាផ្នែកច្បាប់ និងទីប្រឹក្សាផ្នែកបច្ចេកទេស ឆ្លើយតបទៅនឹងតម្រូវការការងារដើម្បីជានាឱ្យបាននូវនីត្យានុកូលភាព ធម្មានុរូប ភាពត្រឹមត្រូវ នៃការសិក្សាស្រាវជ្រាវ និងលើកយោបល់ជូនថ្នាក់ដឹកនាំលើកិច្ចការពាក់ព័ន្ធបច្ចេកទេសច្បាប់

- ការយល់ដឹង និងសមត្ថភាពបំពេញការងាររបស់មន្ត្រីនៅមានកម្រិត ដែលទាមទារឱ្យមានការស្រាវជ្រាវ អភិវឌ្ឍន៍ និងបណ្តុះបណ្តាលបន្ថែមជាប់ជាប្រចាំដើម្បីឆ្លើយតបនឹងសំណូមពរការងារ ព្រមទាំងរៀបចំផែនការបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពមន្ត្រីរយៈពេលខ្លី មធ្យម និងរយៈពេលវែង ដោយសហការជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋាន

- ថវិកាមានកម្រិតបើធៀបនឹងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីចុះពង្រឹង គាំទ្រ តាមដានត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិ ពោលគឺពុំទាន់មានធនធានហិរញ្ញវត្ថុ និងមធ្យោបាយគ្រប់គ្រាន់សម្រាប់បំពេញការងារដោយរលូននៅឡើយដែលធ្វើឱ្យការអនុវត្តតួនាទីភារកិច្ច ពុំអាចសម្រេចបានការងារមួយចំនួនស្របតាមផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងមហាផ្ទៃ

- ការលើកសំណើសុំអន្តរាគមន៍ និងដោះស្រាយវិវាទដីធ្លីរវាងបុគ្គល និងបុគ្គល រវាងប្រជាពលរដ្ឋជាមួយក្រុមហ៊ុន និងរវាងប្រជាពលរដ្ឋជាមួយអាជ្ញាធរជួបការលំបាកក្នុងការដោះស្រាយដោយសារករណីវិវាទដីធ្លីភាគច្រើនមានភាពស្មុគស្មាញ និងមានប្រវត្តិទំនាស់យូរឆ្នាំ

- សំណើរបស់រដ្ឋបាលរាជធានី ខេត្តមួយចំនួនស្នើសុំគោលការណ៍មកបន្ទាន់ពេកជាហេតុធ្វើឱ្យអគ្គនាយកដ្ឋានពុំមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងលើកយោបល់ ជាពិសេសករណីចេញទៅបំពេញទស្សនកិច្ច និងប្រជុំនៅក្រៅប្រទេស

- រដ្ឋបាលខេត្តផ្ញើរបាយការណ៍ប្រចាំខែស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខេត្តមកក្រសួងមានការយឺតយ៉ាវក្នុងការបូកសរុបជូនថ្នាក់ដឹកនាំក្រសួង

- ការចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ក្រសួង ស្ថាប័នមានចំនួនច្រើន ធ្វើឱ្យមិនមានមន្ត្រីគ្រប់គ្រាន់សម្រាប់បំពេញការងារ និងចូលរួមកិច្ចប្រជុំតាមការអញ្ជើញ។

- អាជ្ញាធរមូលដ្ឋាននៅថ្នាក់ក្រោមជាតិមួយចំនួនពុំបានសិក្សាស្វែងយល់អំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាបានច្បាស់លាស់ក្នុងការអនុវត្តការងារ

- ការចុះបេសកកម្មនៅតាមរាជធានី ខេត្ត ដើម្បីគាំទ្រដល់ការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែជួបបញ្ហាប្រឈម និងការលំបាកមួយចំនួន

៤. វិធានការគោលនយោបាយសម្រាប់រួមចំណែកអនុវត្តយុទ្ធសាស្ត្រអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល

ដើម្បីរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា **អគ្គនាយកដ្ឋានរដ្ឋបាល** បានកំណត់វិធានការគោលនយោបាយចំនួន ៦ គឺ៖**ទី១**-ពង្រឹងកិច្ចការរដ្ឋបាល **ទី២**-ពង្រឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ **ទី៣**-ពង្រឹងកិច្ចការគ្រប់គ្រងសមាគម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជនជាតិដើមភាគតិច និងគណបក្សនយោបាយ **ទី៤**-ការគាំទ្រការផ្តល់សេវារដ្ឋបាល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ **ទី៥**-ពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងរដ្ឋបាលដែនដី និងសហប្រតិបត្តិការជាមួយប្រទេសជាមិត្ត **ទី៦**-កិច្ចការកំណែទម្រង់វិមជ្ឈការ និងវិសហ មជ្ឈការលើការងារគ្រប់គ្រងរដ្ឋបាលដែនដី។

## II. គោលបំណងគោលនយោបាយ

ដើម្បីរួមចំណែកក្នុងការអនុវត្តគោលនយោបាយតាមវិស័យ ពិសេសគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាពកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ *អគ្គនាយកដ្ឋានរដ្ឋបាល* មានគោលបំណងគោលនយោបាយដូចខាងក្រោម ៖

| គោលបំណងគោលនយោបាយ | បម្រើឱ្យគោលដៅយុទ្ធសាស្ត្រណាមួយ និងវិធានការគោលនយោបាយអ្វីខ្លះរបស់រាជរដ្ឋាភិបាល | ស្ថិតនៅក្នុងវិស័យណាមួយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
|---|---|---|
| ដឹកនាំ គ្រប់គ្រងរដ្ឋបាលដែនដី ដើម្បីលើកកម្ពស់សេវាសាធារណៈ និងការអភិវឌ្ឍ | ▪ គោលដៅយុទ្ធសាស្ត្រទី៤៖ បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង។<br>▪ វិធានការគោលនយោបាយទី៤៖ បន្តអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីលើកកម្ពស់ដំណើរការប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ និងធានាបាននូវគុណភាពក្នុងការអនុវត្តអំណាច។ | ▪ បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល ៖ សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម។<br>▪ អភិបាលកិច្ចល្អ ៖ កំណែទម្រង់រដ្ឋបាលសាធារណៈ។ |

## 0721 កម្មវិធីទី១៖ ការគ្រប់គ្រងដែនដី

### 072101 អនុកម្មវិធីទី១៖ ការពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ

### 07210101 ចង្កោមសកម្មភាពទី១៖ ពង្រឹងកិច្ចការរដ្ឋបាល

0721010101 សកម្មភាពទី១៖ ពង្រឹងប្រព័ន្ធការងាររដ្ឋបាលទូទៅរបស់អគ្គនាយកដ្ឋានរដ្ឋបាល

072101010101 អនុសកម្មភាពទី១៖ ការគាំទ្រ សម្របសម្រួលការងាររដ្ឋបាល ការរៀបចំ ការត្រួតពិនិត្យ និងគ្រប់គ្រងឯកសារចេញ-ចូល

072101010102 អនុសកម្មភាពទី២៖ ការសម្របសម្រួលកិច្ចប្រជុំ និងការបែងចែកឯកសារជាប្រចាំ

0721010102 សកម្មភាពទី២៖ ពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍លទ្ធផលការងាររបស់អគ្គនាយក-ដ្ឋានរដ្ឋបាល

0721010103 សកម្មភាពទី៣៖ រៀបចំឯកសារ ធ្វើកិច្ចការបដិសណ្ឋារកិច្ច និងទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋានរដ្ឋបាល

072101010301 អនុសកម្មភាពទី១៖ ការរៀបចំចងក្រងឯកសារជំនួយស្មារតី សុន្ទរកថា និងឯកសារផ្សេងៗជូនថ្នាក់ដឹកនាំ

0721010104 សកម្មភាពទី៤៖ ស្រាវជ្រាវ រៀបចំចងក្រងឯកសារ លិខិតបទដ្ឋានគតិយុត្ត និងគ្រប់គ្រងបណ្ណសារដ្ឋាន

0721010105 សកម្មភាពទី៥៖ ចុះតាមដានស្វែងយល់ និងពង្រឹងសមត្ថភាពក្រុមការងារ យេនឌ័រអគ្គនាយក-ដ្ឋានរដ្ឋបាល

0721010106 សកម្មភាពទី៦៖.ការគ្រប់គ្រងធនធានមនុស្សនៅអគ្គនាយកដ្ឋានរដ្ឋបាល និងថ្នាក់ក្រោមជាតិ

072101010601 អនុសកម្មភាពទី១៖ ការចុះតាមដាន វាយតម្លៃ និងគាំទ្រការគ្រប់គ្រងបុគ្គលិក នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

072101010602 អនុសកម្មភាពទី២៖ សហការចុះរៀបចំ និងសម្របសម្រួលពិធីប្រកាសតែងតាំង និងផ្ទេរភារកិច្ចអភិបាល និងអភិបាលរងរាជធានី ខេត្ត

072101010603 អនុសកម្មភាពទី៣៖ ការរៀបចំការគាំទ្រកិច្ចការរដ្ឋបាលទូទៅ និងការពង្រឹងសមត្ថភាពមន្ត្រីរាជការស៊ីវិលនៃអគ្គនាយកដ្ឋានរដ្ឋបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ

072101010604 អនុសកម្មភាពទី៤៖ ការសិក្សា ស្រាវជ្រាវ និងរៀបចំក្របខណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នានាពាក់ព័ន្ធនឹងមន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

0721010107 សកម្មភាពទី៧៖.ការគ្រប់គ្រង សម្របសម្រួល និងគាំទ្រការងារពាក់ព័ន្ធក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

072101010701 អនុសកម្មភាពទី១៖ ការសម្របសម្រួល និងគាំទ្រការងារពាក់ព័ន្ធនឹងសមាជិកក្រុមប្រឹក្សារដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

072101010702 អនុសកម្មភាពទី២៖ ការបោះពុម្ពប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណសរសើរសម្រាប់មន្ត្រីរាជការស៊ីវិលនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

072101010703 អនុសកម្មភាពទី៣៖ ការងារគ្រប់គ្រង:លីកិច្ចដំណើរការការិយាល័យក្រុមប្រឹក្សា

| | |
|---|---|
| 0721010108 | សកម្មភាពទី៨៖ គ្រប់គ្រង ពង្រឹង និងត្រួតពិនិត្យ តាមដាន វាយតម្លៃកិច្ចការហិរញ្ញវត្ថុ ការអនុវត្តថវិកា និងសារពើភណ្ឌ ទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយកដ្ឋានរដ្ឋបាល |
| 072101010801 | អនុសកម្មភាពទី១៖រៀបចំការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា |
| 072101010802 | អនុសកម្មភាពទី២៖ ការសម្របសម្រួលកិច្ចប្រជុំ និងការរៀបចំឯកសារគាំទ្រ |
| 072101010803 | អនុសកម្មភាពទី៣៖ ការការចំណាយសម្រាប់មធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូន |
| **07210102** | **ចង្កោមសកម្មភាពទី២៖ ពង្រឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងសហប្រតិបត្តិការ** |
| 0721010201 | សកម្មភាពទី១៖ ពង្រឹងប្រសិទ្ធភាពការអនុវត្តតួនាទី ភារកិច្ចរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| 072101020101 | អនុសកម្មភាពទី១៖ កិច្ចប្រជុំពិភាក្សាជាមួយរដ្ឋបាលរាជធានី ខេត្ត ស្តីពីការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| 072101020102 | អនុសកម្មភាពទី២៖ កិច្ចប្រជុំពង្រឹងប្រសិទ្ធភាពនៃការអនុវត្តតួនាទី និងភារកិច្ចរបស់រដ្ឋបាលក្រុង ស្រុក |
| 072101020103 | អនុសកម្មភាពទី៣៖ បេសកកម្មក្រៅប្រទេស |
| 072101020104 | អនុសកម្មភាពទី៤៖ សម្ភារៈ បរិក្ខារបច្ចេកទេស សម្រាប់គាំទ្រដល់ការិយាល័យជំនាញ |
| 0721010202 | សកម្មភាពទី២៖ គាំទ្រលើការរៀបចំ និងអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| 072101020201 | អនុសកម្មភាពទី១៖ សិក្ខាសាលាពិគ្រោះយោបល់លើការកែសម្រួលសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ |
| 072101020202 | អនុសកម្មភាពទី២៖ សិក្ខាសាលាផ្សព្វផ្សាយសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ |
| 072101020203 | អនុសកម្មភាពទី៣៖ កិច្ចប្រជុំពិគ្រោះយោបល់លើការរៀបចំឧបករណ៍ចុះសិក្សាស្រាវជ្រាវ និងតាមដានអំពីការអនុវត្តគោលនយោបាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| 072101020204 | អនុសកម្មភាពទី៤៖ ចុះគាំទ្រដល់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ក្នុងការអនុវត្តគោលនយោបាយនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន |
| 072101020205 | អនុសកម្មភាពទី៥៖ ចុះគាំទ្រដល់រដ្ឋបាលរាជធានី ខេត្ត ក្នុងការរៀបចំនិមិត្តសញ្ញារដ្ឋបាលឃុំ សង្កាត់ |
| 0721010203 | សកម្មភាពទី៣៖ គាំទ្រ តម្រង់ទិស តាមដាន ត្រួតពិនិត្យការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុក ឃុំ សង្កាត់ |
| 072101020301 | អនុសកម្មភាពទី១៖ វគ្គតម្រង់ទិសស្តីពីការអនុវត្តគម្រោងថវិកាសេវាសង្គមរបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| 072101020302 | អនុសកម្មភាពទី២៖ ចុះតាមដានត្រួតពិនិត្យការរៀបចំថវិកាក្រុង ស្រុក ឃុំ សង្កាត់ |
| 072101020303 | អនុសកម្មភាពទី៣៖ ចុះតាមដានត្រួតពិនិត្យការអនុវត្តថវិកាក្រុង ស្រុក ឃុំ សង្កាត់ |
| 072101020304 | អនុសកម្មភាពទី៤៖ ចុះតាមដានត្រួតពិនិត្យការបិទបញ្ជីថវិកាក្រុង ស្រុក ឃុំ សង្កាត់ |

| | |
|---|---|
| 0721010204 | សកម្មភាពទី៤៖ ពង្រឹងប្រសិទ្ធភាពប្រព័ន្ធផែនការថ្នាក់ក្រោមជាតិ |
| 072101020401 | អនុសកម្មភាពទី១៖ រៀបចំ និងសម្រួលការធ្វើសេចក្ដីណែនាំ និងផ្សព្វផ្សាយសេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងសេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល |
| 072101020402 | អនុសកម្មភាពទី២៖ ចុះតាមដាន និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ លើការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ |
| 0721010205 | សកម្មភាពទី៥៖ គាំទ្រ សម្របសម្រួល ណែនាំ តម្រង់ទិស តាមដាន ត្រួតពិនិត្យការរៀបចំ និងការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់ |
| 072101020501 | អនុសកម្មភាពទី១៖ ចុះតាមដានការរៀបចំ និងការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់ |
| 072101020502 | អនុសកម្មភាពទី២៖ ចុះតាមដានការរៀបចំកិច្ចប្រជុំបើកសំណើរដេញថ្លៃគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់ |
| 0721010206 | សកម្មភាពទី៦៖ ពង្រឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| 072101020601 | អនុសកម្មភាពទី១៖ រៀបចំឧបករណ៍វាយតម្លៃលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋលើការផ្ដល់សេវារដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| 072101020602 | អនុសកម្មភាពទី២៖ រៀបចំប្រព័ន្ធរបាយការណ៍អនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ឱ្យប្រើប្រាស់តាមអនឡាញ |
| 072101020603 | អនុសកម្មភាពទី៣៖ ចុះតាមដាន ត្រួតពិនិត្យ វាយតម្លៃការបំពេញតួនាទី ភារកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| 0721010207 | សកម្មភាពទី៧៖ ការពង្រឹងសមត្ថភាពលើការផ្ដល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| 072101020701 | អនុសកម្មភាពទី១៖ សិក្ខាសាលាបូកសរុបលទ្ធផលនៃការផ្ដល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនិងការសម្រុះសម្រួលដោះស្រាយបណ្ដឹងតាមយន្តការការិយាល័យប្រជាពលរដ្ឋ |
| 072101020701 | សកម្មភាពទី៨៖ ការគាំទ្រកិច្ចប្រតិប្រត្តិការរបស់នាយកដ្ឋាន |
| 072101020801 | អនុសកម្មភាពទី១៖ ការចូលរួមកិច្ចប្រជុំ និងទស្សនកិច្ចសិក្សា |
| 072101020802 | អនុសកម្មភាពទី២៖ ការចំណាយសម្រាប់គាំទ្រប្រតិប្រត្តិការរបស់នាយកដ្ឋាន |
| 0721010209 | សកម្មភាពទី៩៖ ពង្រឹងប្រព័ន្ធគ្រប់គ្រងការងាររដ្ឋបាល |
| 072101020901 | អនុសកម្មភាពទី១៖ រៀបចំកិច្ចប្រជុំស្ដីពីផែនការសកម្មភាព និងថវិការបស់នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត ប្រចាំឆ្នាំ២០២៧ |
| 072101020902 | អនុសកម្មភាពទី២៖ គាំទ្រសម្ភារៈដល់ដំណើរការរដ្ឋបាលរបស់នាយកដ្ឋាន |
| 0721010210 | សកម្មភាពទី១០៖ ការពង្រឹងរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត |
| 072101021001 | អនុសកម្មភាពទី១ ៖សហការចុះសិក្សាលក្ខណៈវិនិច្ឆ័យដើម្បីប្រែក្លាយខេត្តទៅជារដ្ឋបាលតំបន់ និងរាជធានី ទៅជាទីក្រុងមេត្រូប៉ូលីតែន និងលក្ខណៈវិនិច្ឆ័យរបស់រដ្ឋបាលក្រុង និងលក្ខណៈវិនិច្ឆ័យរបស់រដ្ឋបាលសង្កាត់ចំណុះស្រុក (២.១.១ ផសថ គជអប) |

072101021002 អនុសកម្មភាពទី២ ៖ រៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការបង្កើត ការលុបចោល និងការកែសម្រួលព្រំប្រទល់រដ្ឋបាល

072101021003 អនុសកម្មភាពទី៣៖ រៀបចំប្រកាសស្តីពីលក្ខណៈវិនិច្ឆ័យរបស់ភូមិ

072101021004 អនុសកម្មភាពទី៤៖ ពិនិត្យលើសំណើការបង្កើត ការលុបចោល ការកែសម្រួលព្រំប្រទល់ និងការកំណត់ឈ្មោះរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

072101021005 អនុសកម្មភាពទី៥៖ រៀបចំយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ទីក្រុងឆ្លាត (២.១.១.៥ ផសប៉ គជអប)

072101021006 អនុសកម្មភាពទី៦៖ រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះអន្តរក្រសួងប្រមូលធាតុចូលស្តីពីយុទ្ធសាស្ត្រជាតិសម្រាប់រៀបចំអភិវឌ្ឍន៍ទីក្រុងឆ្លាត (Smart City)

072101021007 អនុសកម្មភាពទី៧៖ ចូលរួមកិច្ចប្រជុំបណ្តាញទីក្រុងឆ្លាតអាស៊ានប្រចាំឆ្នាំនិងកិច្ចប្រជុំអាស៊ាន ជប៉ុន និងសិក្ខាសាលាបណ្តុះបណ្តាលនៅក្រៅប្រទេស

072101021008 អនុសកម្មភាពទី៨៖ សហការចុះរៀបចំ និងអនុវត្តគោលនយោបាយ និងផែនការការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រោមជាតិ ព្រមទាំងការជំរុញនិងពង្រឹងការរៀបចំនិងការអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានី ខណ្ឌ និងក្រុង និងផែនការប្រើប្រាស់ដីខេត្ត

072101021009 អនុសកម្មភាពទី៩៖ សហការរៀបចំកិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

072101021010 អនុសកម្មភាពទី១០៖ សហការចុះរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត

0721010211 សកម្មភាពទី១១៖ ការលើកកម្ពស់តួនាទី ភារកិច្ចរបស់រដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត

072101021101 អនុសកម្មភាពទី១៖ សហការចុះលើកកម្ពស់ការអនុវត្តការងាររបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត

072101021102 អនុសកម្មភាពទី២៖ សិក្សាការរៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងការផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយគ្រប់ប្រភេទនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

072101021103 អនុសកម្មភាពទី៣៖ ការចុះសហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធអំពីការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

072101021104 អនុសកម្មភាពទី៤៖ សិក្សាស្រាវជ្រាវ តាមដាន និងការគាំទ្រដល់ការងាររបស់គណៈកម្មការចំពោះកិច្ច ដើម្បីដោះស្រាយបញ្ហាផ្ទះបណ្តែតទឹក និងបែរចិញ្ចឹមត្រី ស្ថិតក្នុងភូមិសាស្ត្រខេត្តទាំង ៥ ជុំវិញបឹងទន្លេសាប

072101021105 អនុសកម្មភាពទី៥៖ ការចុះសិក្សាស្រាវជ្រាវ តាមដាន និងដោះស្រាយបណ្តឹងនានាពាក់ព័ន្ធនឹងការអនុវត្តតួនាទី ភារកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត

072101021106 អនុសកម្មភាពទី៦៖ ការចុះគាំទ្រ សម្របសម្រួល ដល់ដំណើរការរៀបចំសន្និបាតបូកសរុបលទ្ធផលការងាររបស់រាជធានី ខេត្ត

072101021107 អនុសកម្មភាពទី៧៖ ការសហការចុះ និងសម្របសម្រួលដល់ការរៀបចំ និងដំណើរការនៃការងារបោះឆ្នោត

072101021108 អនុសកម្មភាពទី៨៖ សិក្សាស្រាវជ្រាវ សម្របសម្រួល តាមដាន និងគាំទ្រពាក់ព័ន្ធនឹងការងារ

សេដ្ឋកិច្ច ការងារសង្គមកិច្ច ការងារដីធ្លី ការងារបរិស្ថាន ការងារធនធានធម្មជាតិ ការងារវិនិយោគ ការងារគ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងការដោះស្រាយវិវាទមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| | |
|---|---|
| 072101021109 | អនុសកម្មភាពទី៩៖ បន្សីរវាងប្រតិទិនការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាមួយគម្រោងថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត ខណ្ឌ |
| 072101021110 | អនុសកម្មភាពទី១០៖ រៀបចំសេចក្តីព្រាងអនុក្រឹត្យរៀបចំគម្រោងរាជធានី ខេត្ត និងខណ្ឌ |
| 072101021111 | អនុសកម្មភាពទី១១៖ សហការរៀបចំច្បាប់ហិរញ្ញវត្ថុ ថវិកាភាតរភាព ផែនការយុទ្ធសាស្ត្រ គម្រោងវិនិយោគសាធារណៈ ២០២៥-២០២៨ |
| 0721010212 | សកម្មភាពទី១២៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត |
| 072101021201 | អនុសកម្មភាពទី១៖ ចុះតាមដាន ត្រួតពិនិត្យ និងលើកកម្ពស់ការអនុវត្តគម្រោងអភិវឌ្ឍន៍ និងលទ្ធកម្ម នៅ ២៥ រដ្ឋបាលរាជធានី ខេត្ត និង១៤រដ្ឋបាលខណ្ឌ |
| 072101021202 | អនុសកម្មភាពទី២៖ សហការចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការបំពេញតួនាទី ភារកិច្ចនៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែន |
| 072101021203 | អនុសកម្មភាពទី៣៖ ចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងាររបស់រដ្ឋបាលរាជធានីខេត្ត |
| 072101021204 | អនុសកម្មភាពទី៤៖ ចុះសិក្សាស្រាវជ្រាវ តាមដានពិនិត្យ ពាក់ព័ន្ធនឹងមតិយោបល់ ឬសំណូមពររបស់មហាជនក្នុងគេហទំព័រហ្វេសប៊ុក |
| 072101021205 | អនុសកម្មភាពទី៥៖ ចុះតាមដាន ត្រួតពិនិត្យវាយតម្លៃដំណើរការរៀបចំកិច្ចប្រជុំ និងការរៀបចំវេទិកាសាធារណៈរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ខណ្ឌ (២.២.២.២ ផសថ គជអប) |
| 0721010213 | សកម្មភាពទី១៣៖ ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងតាមប្រព័ន្ធឌីជីថល |
| 072101021301 | អនុសកម្មភាពទី១៖ រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានគម្រោង (PID) របស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមឌីជីថល |
| 0721010214 | សកម្មភាពទី១៤៖ ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| 072101021401 | អនុសកម្មភាពទី១៖ ចុះសហការផ្តល់ការគាំទ្រដល់រដ្ឋបាលខេត្តនៅក្នុងការគ្រប់គ្រងព្រំដែន និងពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងខេត្តនិងខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង |
| 072101021402 | អនុសកម្មភាពទី២៖ ចូលរួមកិច្ចប្រជុំលើកទី១៤ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនរវាងកម្ពុជា-វៀតណាម នៅប្រទេសវៀតណាម |
| 072101021403 | អនុសកម្មភាពទី៣៖ រៀបចំកិច្ចប្រជុំបូកសរុប វាយតម្លៃ និងដាក់ចេញវិធានការក្នុងការពង្រឹងការងារកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលរាជធានី ខេត្ត |
| 0721010215 | សកម្មភាពទី១៥៖ លើកកម្ពស់ការគ្រប់គ្រងច្រកទ្វារព្រំដែន និងចូលរួមអភិវឌ្ឍន៍តំបន់ព្រំដែន |
| 072101021501 | អនុសកម្មភាពទី១៖ ចុះសិក្សារៀបចំបង្កើត ដំឡើងកម្រិត លុបចោល និងបិទច្រកទ្វារព្រំដែនជាមួយបណ្តាប្រទេសជិតខាង ចំនួន៥ច្រក |
| 072101021502 | អនុសកម្មភាពទី២៖ រៀបចំកិច្ចប្រជុំពិនិត្យតួនាទីការបំពេញតួនាទី ភារកិច្ចនៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែន |

| | |
|---|---|
| 072101021503 | អនុសកម្មភាពទី៣៖ ចុះសិក្សាគម្រោងការសាងសង់អគារនិងហេដ្ឋារចនាសម្ព័ន្ធទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែននៅតាមបណ្តាច្រកព្រំដែន |
| 072101021504 | អនុសកម្មភាពទី៤៖រៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែននៅទូទាំងប្រទេស ជំនួសឱ្យអនុក្រឹត្យលេខ ៦៤ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ |
| 072101021505 | អនុសកម្មភាពទី៥៖ រៀបចំកិច្ចប្រជុំពិនិត្យសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម ក្នុប្រទេស(កិច្ចប្រជុំផ្ទៃក្នុង និងកិច្ចប្រជុំនៅវៀតណាម) |
| 072101021506 | អនុសកម្មភាពទី៦៖ សិក្សា និងរៀបចំក្របខណ្ឌគតិយុត្តនៅក្នុងការបង្កើត និងដាក់ឱ្យដំណើរការនូវបណ្ណព្រំដែន កម្ពុជា-វៀតណាម |
| **07210103** | **ចង្កោមសកម្មភាពទី៣៖ ពង្រឹងកិច្ចការគ្រប់គ្រងសមាគម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជនជាតិដើមភាគតិច និងគណបក្សនយោបាយ** |
| 0721010301 | សកម្មភាពទី១៖ រៀបចំវេទិកា ឬកិច្ចប្រជុំផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសមាគម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជនជាតិដើមភាគតិច និងគណបក្សនយោបាយ |
| 0721010302 | សកម្មភាពទី២៖ ពិនិត្យ និងលើកយោបល់លើសំណើសុំនានារបស់សមាគម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជនជាតិដើមភាគតិច និងគណបក្សនយោបាយ |
| 0721010303 | សកម្មភាពទី៣៖ ធ្វើបច្ចុប្បន្នកម្មទិន្នន័យរបស់សមាគម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជនជាតិដើមភាគតិច និងគណបក្សនយោបាយទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា |
| 0721010304 | សកម្មភាពទី៤៖ សម្របសម្រួលកិច្ចការរដ្ឋបាលរបស់នាយកដ្ឋាន |
| **07210104** | **ចង្កោមសកម្មភាពទី៤៖ កិច្ចការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** |
| 0721010401 | សកម្មភាពទី១៖ ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ |
| 072101040101 | អនុសកម្មភាពទី១៖ ការចុះតាមដាន និងគាំទ្រការអនុវត្តមុខងារដែលបានផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| 0721010402 | សកម្មភាពទី២៖ ការពង្រឹងយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| 072101040201 | អនុសកម្មភាពទី១៖ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត |
| 072101040202 | អនុសកម្មភាពទី២៖ ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ |
| 072101040203 | អនុសកម្មភាពទី៣៖ ការគាំទ្រ និងការតាមដាន ត្រួតពិនិត្យ វាយតម្លៃការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ |
| 0721010403 | សកម្មភាពទី៣៖ ការពង្រឹងការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| 072101040301 | អនុសកម្មភាពទី១៖ ការពង្រឹងសមត្ថភាពដល់ការិយាល័យប្រជាពលរដ្ឋ |
| 072101040302 | អនុសកម្មភាពទី២៖ ការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ |

## III. ការរៀបចំអនុកម្មវិធី

ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើឱ្យទទួលបានជោគជ័យ **អគ្គនាយកដ្ឋានរដ្ឋបាល** បានចូលរួម រៀបចំ គ្រប់គ្រង និងដឹកនាំអនុកម្មវិធីចំនួន១ ក្នុងកម្មវិធីទី១ របស់ក្រសួងមហាផ្ទៃ (ការគ្រប់គ្រងរដ្ឋបាលដែនដី) ដូចខាងក្រោម ៖

**អគ្គនាយដ្ឋានរដ្ឋបាល៖**

**តារាង ១: កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវ**

| ឈ្មោះ គោលបំណង គោលនយោបាយ | ឈ្មោះ កម្មវិធី និង អនុកម្មវិធី | អ្នកគ្រប់គ្រង | អង្គភាពទទួលខុសត្រូវ | | | |
|---|---|---|---|---|---|---|
| | | | ឈ្មោះអង្គភាព | (១) | (២) | (៣) |
| ➢ គោលបំណងគ.ប ទី១: ដឹកនាំ គ្រប់គ្រងរដ្ឋបាលដែនដីដើម្បីលើកកម្ពស់សេវាសាធារណៈ និងការអភិវឌ្ឍ | ▪ **កម្មវិធីទី១៖ ការគ្រប់គ្រងរដ្ឋបាលដែនដី**<br>• អនុកម្មវិធីទី១៖ ការពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ | ឯកឧត្តម សូស ប្រាថ្នា | អគ្គនាយកដ្ឋានរដ្ឋបាល | | | |
| | ❖ ចង្កោមសកម្មភាពទី១៖ ពង្រឹងកិច្ចការរដ្ឋបាល | លោកស្រី ហេង ពៅធីតា | នាយកដ្ឋានរដ្ឋបាលសរុប | | | |
| | ❖ ចង្កោមសកម្មភាពទី២៖ ពង្រឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងសហប្រតិបត្តិការ | លោក លី យ៉ាសាក់<br><br>លោក អ៊ឹង កែវរតនៈ | នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់<br><br>នាយកដ្ឋានមុខងារ និងធនធាន | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | លោក ឆាង ច័យ | នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខេត្ត និងខណ្ឌ | | | |
| | ❖ ចង្កោមសកម្មភាពទី៣៖ ពង្រឹងកិច្ចការគ្រប់គ្រងសមាគម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជនជាតិដើមភាគតិច និងគណបក្សនយោបាយ | លោក គាន ណារិន | នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ | | | |
| | ❖ ចង្កោមសកម្មភាពទី៤៖ កិច្ចការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | លោក អ៊ុង កែវគេនៈ | នាយកដ្ឋានមុខងារ និងធនធាន | | | |

(*) ជាគោលការណ៍ ចំនួនគោលបំណងគោលនយោបាយ មិនត្រូវមានលើសពី ២ ឡើយ។ ក្នុងករណី ក្រសួង-ស្ថាប័នដែលមានមុខងារច្រើន អាចត្រូវបានអនុញ្ញាតឱ្យមាន គោលបំណងគោលនយោបាយលើសពី ២ ប៉ុន្តែជាកម្មវត្ថុនៃការពិភាក្សា និងឯកភាពជាមុនពី គសហវ ។

(**) ជាគោលការណ៍ ចំនួនកម្មវិធី មិនត្រូវមានលើសពី ៥ ឡើយ។ ក្នុងករណី ក្រសួង-ស្ថាប័នធំៗ ដែលមានមុខងារច្រើន អាចត្រូវបានអនុញ្ញាតឱ្យមានកម្មវិធីលើសពី ៥ ប៉ុន្តែជាកម្មវត្ថុនៃការពិភាក្សា និង ឯកភាពជាមុនពីគសហវ។

(***) សូមដាក់ (√) ដូចតទៅ៖ (១) អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ (២) អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និង (៣) មិនមែនជាអង្គភាពថវិកា។

## IV. ការកំណត់រចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម

### ក. ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅ

អគ្គនាយដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានកំណត់នូវសូចនាករ និងគោលដៅសូចនាករ ដើម្បីតាមដានវឌ្ឍនភាព និងសមិទ្ធិផលនៃការអនុវត្តកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព ដូចខាងក្រោម ៖

**ការកំណត់សូចនាករសមិទ្ធកម្ម និង គោលដៅ នៃកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព**

| សេចក្តីពណ៌នា (បន្ថែមជួរដេកមួយសម្រាប់សូចនាករចុងក្រោយ និងសូចនាករលទ្ធផលក្នុងឆ្នាំនីមួយៗ) | គម្រោងថវិកាឆ្នាំ២០២៦ | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំអនុវត្តឆ្នាំ២០២៤ (សម្រេចបាន) | ឆ្នាំបច្ចុប្បន្នឆ្នាំ ២០២៥ | ឆ្នាំគ្រោងថវិកា ២០២៦ | | ឆ្នាំគ្រោងថវិកា ២០២៧ | ឆ្នាំគ្រោងថវិកា ២០២៨ |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅឆ្នាំ២០២៥) | | |
| **១. កម្មវិធីទី១:ការគ្រប់គ្រងរដ្ឋបាលដែនដី** | 1,259,800,000.00៛ | | | | | | |
| *សូចនាករលទ្ធផលចុងក្រោយទី ១ :*<br>*-ស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិមានភាពល្អប្រសើរជាងមុន* | | ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានប្រសិទ្ធភាពជាងមុន | ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានប្រសិទ្ធភាពជាងមុន | ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានប្រសិទ្ធភាពជាងមុន | | ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានប្រសិទ្ធភាពជាងមុន | ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានប្រសិទ្ធភាពជាងមុន |
| *សូចនាករលទ្ធផលចុងក្រោយទី ២ :*<br>*-ការផ្តល់សេវាសាធារណៈកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព* | | ចំនួនការិយាល័យច្រកចេញចូល | ចំនួនការិយាល័យច្រកចេញចូល | ចំនួនការិយាល័យច្រកចេញចូល | | ចំនួនការិយាល័យច្រកចេញចូល | ចំនួនការិយាល័យច្រកចេញចូលតែមួយ និង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| *ភាពជាងមុន* | | តែមួយ និង ការិយាល័យប្រជាពលរដ្ឋមានការកើនឡើងបន្ថែមទៀត | តែមួយ និង ការិយាល័យប្រជាពលរដ្ឋមានការកើនឡើងបន្ថែមទៀត | តែមួយ និង ការិយាល័យប្រជាពលរដ្ឋមានការកើនឡើងបន្ថែមទៀត | | តែមួយ និង ការិយាល័យប្រជាពលរដ្ឋមានការកើនឡើងបន្ថែមទៀត | ការិយាល័យប្រជាពលរដ្ឋមានការកើនឡើងបន្ថែមទៀត |
| **១.១. អនុកម្មវិធីទី១៖ ការពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ** | 1,259,800,000.00៛ | | | | | | |
| ***សូចនាករលទ្ធផលក្នុងឆ្នាំទី ១:*** *-ចំនួនលិខិតបទដ្ឋានគតិយុត្តគាំទ្រដល់កិច្ចការនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រេចបាន* | | ១៤លិខិត | ១៤លិខិត | ១៤លិខិត | | ១៤លិខិត | ១៤លិខិត |
| *-ចំនួនសេវារដ្ឋបាលសាធារណៈដែលបានផ្តល់ជូនប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រេចបានល្អប្រសើរ និងទាន់ពេលវេលា* | | ៣០០០០០០ សេវា | ៣០០០០០០ សេវា | ៣០០០០០០ សេវា | | ៣០០០០០០ សេវា | ៣០០០០០០ សេវា |
| ❖ ១.១.១.ច.កទី១៖ ពង្រឹងកិច្ចការ រដ្ឋបាល | 485,127,885.00៛ | | | | | | |
| ***សូចនាករលទ្ធផលក្នុងឆ្នាំទី ១:*** *-ស្ថានភាពប្រព័ន្ធគ្រប់គ្រងកិច្ចការរដ្ឋបាលថ្នាក់ជាតិត្រូវបានជំរុញឱ្យកាន់តែប្រសើរ* | | បានទាន់ពេលវេលា | បានទាន់ពេលវេលា | បានទាន់ពេលវេលា | | បានទាន់ពេលវេលា | បានទាន់ពេលវេលា |
| ***សូចនាករលទ្ធផលក្នុងឆ្នាំទី ២:*** *-ចំនួនប្រព័ន្ធគ្រប់គ្រងការទទួល បញ្ជូន* | | ០ប្រព័ន្ធ | ១ប្រព័ន្ធ | ១ប្រព័ន្ធ | | ១ប្រព័ន្ធ | ១ប្រព័ន្ធ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| *ឯកសារត្រូវបានរៀបចំបានត្រឹមត្រូវ* | | | | | | | |
| ***សូចនាករលទ្ធផលក្នុងឆ្នាំទី ៣:*** *-ចំនួនច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត គាំទ្រដល់កិច្ចការនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានព្រាង និងអនុម័តតាមកាលកំណត់* | | ១៤ច្បាប់ | ១៤ច្បាប់ | ១៤ច្បាប់ | | ១៤ច្បាប់ | ១៤ច្បាប់ |
| **១.១.១.១. ស.កទី១៖** ពង្រឹងប្រព័ន្ធការងាររដ្ឋបាលទូទៅរបស់អគ្គនាយកដ្ឋានរដ្ឋបាល | 102,075,900.00៛ | | | | | | |
| ***សូចនាករលទ្ធផលក្នុងឆ្នាំទី ១:*** *-ចំនួនឯកសារចេន្តចេញចូលក្នុងអគ្គនាយកដ្ឋានរដ្ឋបាល* | | ១០.១០២ ច្បាប់ | ១០.១០២ ច្បាប់ | ១០.១០២ ច្បាប់ | | ១០.១០២ ច្បាប់ | ១០.១០២ ច្បាប់ |
| ***សូចនាករលទ្ធផលក្នុងឆ្នាំទី ២:*** *-ចំនួនកិច្ចប្រជុំពង្រឹងការគ្រប់គ្រង់និងបែងចែកឯកសារ អគ្គនាយកដ្ឋានរដ្ឋបាល* | | ១២លើក | ១២លើក | ១២លើក | | ១២លើក | ១២លើក |
| **១.១.១.២. ស.កទី២៖** ពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍លទ្ធផលការងាររបស់អគ្គនាយកដ្ឋានរដ្ឋបាល | 74,419,600.00៛ | | | | | | |
| ***សូចនាករលទ្ធផលក្នុងឆ្នាំទី ១:*** *-ចំនួនរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំត្រូវបានរៀបចំ* | | ១៦លើក | ១៦លើក | ១៦លើក | | ១៦លើក | ១៦លើក |
| **១.១.១.៣. ស.កទី៣៖** រៀបចំឯកសារ ធ្វើកិច្ចការបេជិសណ្ឋារកិច្ច | 41,561,000.00៛ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| និងទំនាក់ទំនងសាធារណៈរបស់ អគ្គនាយកដ្ឋានរដ្ឋបាល | | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ១: -ចំនួនបដិសណ្ឋារកិច្ចរបស់ អគ្គនាយកដ្ឋានរដ្ឋបាលត្រូវបានរៀបចំ* | | ៦៤លើក | ៦៤លើក | ៦៤លើក | | ៦៤លើក | ៦៤លើក |
| **១.១.១.៤. ស.កទី៤៖** ស្រាវជ្រាវ រៀបចំចងក្រងឯកសារ លិខិតបទដ្ឋានគតិយុត្ត និងគ្រប់គ្រងបណ្ណសារដ្ឋាន | 12,959,505.00៛ | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ១: -ចំនួនឯកសារ លិខិតបទដ្ឋានគតិយុត្ត ត្រូវបានចងក្រង និងគ្រប់គ្រងបានត្រឹមត្រូវ* | | ៥០០០ ឯកសារ | ៥០០០ ឯកសារ | ៥០០០ ឯកសារ | | ៥០០០ ឯកសារ | ៥០០០ ឯកសារ |
| **១.១.១.៥. ស.កទី៥៖** ចុះតាមដានស្វែងយល់ និងពង្រឹងសមត្ថភាពក្រុមការងារយេនឌ័រ អគ្គនាយកដ្ឋានរដ្ឋបាល | 27,340,000.00៛ | | | | | | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ១: -ចំនួនគោលដៅបេសកកម្មស្ដីពីការងារយេនឌ័រដែលត្រូវបានចុះពង្រឹង និងអនុវត្ត* | | ២៤ ខេត្ត/ក្រុង | ២៤ ខេត្ត/ក្រុង | ២៤ ខេត្ត/ក្រុង | | ២៤ ខេត្ត/ក្រុង | ២៤ ខេត្ត/ក្រុង |
| **១.១.១.៦. ស.កទី៦៖** ការគ្រប់គ្រងធនធានមនុស្សនៅ អគ្គនាយកដ្ឋានរដ្ឋបាល និងថ្នាក់ក្រោមជាតិ | 92,189,140.00៛ | | | | | | |
| *ចនាករលទ្ធផលក្នុងឆ្នាំទី ១:* | | ២៥រាជធានី/ | ២៥រាជធានី/ | ២៥រាជធានី/ | | ២៥រាជធានី/ | ២៥រាជធានី/ |

| | | | | | | | |
|---|---|---|---|---|---|---|---|
